# រឿងល្ខោន
# ពិសោធន៍ស្នេហា



រឿងល្ខោននិយាយ

# ពិសោធន៍ស្នេហា

រៀបរៀងដោយ

**ហង្ស ធុនហាក់ ហង់ ជួន និង ជឹក សំផេន**

ដោយមានសហជីវិន

ហ៊ែល-សំផា និង អ៊ុក-អុង

ជាអ្នកប្រឹក្សា

ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ

# ជូនចំពោះមិត្តអ្នកអាន

ខ្ញុំសម្រេចបោះផ្សាយរឿងល្ខោននិយាយ“ពិសោធន៍ស្នេហា” នេះឡើងវិញ ដើម្បីឧទ្ទិសដល់បុព្វបុរសខ្មែរជំនាន់មុនផង ជាពិសេសដល់បិតារបស់ខ្ញុំ ដែលធ្លាប់បម្រើការនៅក្នុងវិស័យវប្បធម៌ផង និងដើម្បីរំលឹកដល់ “ល្ខោននិយាយ” ដែលជាល្ខោនពេញនិយម នៅក្នុងទសវត្សឆ្នាំ១៩៥០ និង ១៩៦០។

ក្រោយពេលទទួលបានឯករាជ្យ បញ្ញវន្តជាច្រើនបានខិតខំតែងនិពន្ធ ហើយបានបង្កើតជាចលនាអក្សរសិល្ប៍ដែលយើងហៅថា **អក្សរសិល្ប៍ខេមរនិយម**។

ខ្ញុំសង្ឃឹមថាតាមរយៈស្នាដៃនេះ អ្នកនិពន្ធជំនាន់ក្រោយអាចសិក្សាពីចលនាល្ខោននិយាយនេះ ហើយនិស្សិតនៃសាកលវិទ្យាល័យវិចិត្រសិល្បៈអាចបង្កើតឡើងវិញនូវល្ខោននិយាយដែលធ្លាប់ពេញនិយមនៅកម្ពុជា។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

*( បាត់ខ្លឹមសារអត្ថបទទំព័រទី១ )*

ដែលពិតប្រាកដនោះគឺរាត្រីថ្ងៃសៅរ៍ រាត្រីថ្ងៃសៅរ៍យើងកន្លងផុតទៅហើយ ដូច្នេះអាទិត្យពិតប្រាកដនោះយើងក៏អស់ទៅហើយដែរ។

**ប៉ូល ៖** តែពួកយើងមិនបណ្តោយឱ្យពេលវេលាដែលកន្លងផុតទៅ ផ្តល់អផ្សុកដល់យើងបានឡើយ ផឹក រាំ ច្រៀង មើលរឿងអាម្ចូរជក់ តែគិត គិតទៅណា នែ! សង្ហា ផ្ញើអារម្មណ៍តាមផ្សែងបារីទៅណាយីគិតទៅណា សួរមិនឆ្លើយផង។

## ឈប់លេងភ្លេង

**ជីណូ ៖** ទៅ ទៅផ្ទះ! ម្ចាស់គេធុញហើយ មើលគេមិនទាំងឆ្លើយតបនឹងពួកយើងផង។

**លិនដា ៖** សង្ហា! មើណោះ ព្រីស៊ីដបារដូ លែងប្តីទៀតហើយ មិនយល់សោះតែម្តងពួកអាទើសអស់ទាំងហ្នឹង លែងប្តីលែងប្រពន្ធដូចផ្លាស់អាវសីម៉ីសអ៊ីចឹង។

**សង្ហា ៖** មិនមែនតែអាទើសទេ ហើយមិនមែនតែពួកអឺរ៉ុបទេ ទាំងអស់គ្នា។ សារាយនិងតារាឈប់រាំ

នៅសតវត្សទី២០ យើងនេះ សតវត្សបរមាណូ សតវត្សស្ពុតនិក សេចក្ដីស្នេហាលែងមានន័យ លែងមានមូលដ្ឋានបរិសុទ្ធអស់ហើយ គ្មានទេ រ៉ូមេអូ ហ្ស៊ុលលីយេត ប៉ូលវីរហ្សីនី ទុំទាវ សូម្បីតែព្រះរាម នាងសីតា ក៏គ្មានផង។ ស្នេហាស្ពុតនិក ស្នេហាបរមាណូ គ្រាន់តែបក់ទង្គិចគ្នា ជាជាតិអគ្គិសនីខាងផ្លូវកាមគុណទៅតាមការតម្រេកសាច់ឈាម ហើយក៏បាក់បែក ភ្លាត់ភ្លាំង ព្រាត់ប្រាសចោលគ្នាទៅ។ ចាប់ប្រុសម្នាក់មកសួរមើល តើបានបញ្ឆោតស្រីប៉ុន្មានដង ម្នាក់ៗរាប់មិនអស់ ម្ល៉ោះហើយឱ្យស្រីៗស្នេហាបរិសុទ្ធម៉េចកើត ជំងឺស្នេហានេះវាឆ្លងពីភេទមួយទៅភេទមួយ ពីអឺរ៉ុបមកអាស៊ី ពីប៉ារីសមកភ្នំពេញ។

ប៉ូល ៖ អ៊ីចឹងហើយបានជាគ្នាសុខចិត្ត សារម្លួរតែជាមួយឱបដបស្រា។ យ៉ាងណា ក៏គេមិនក្បត់គ្នាដែរក្លិននៅតែដដែល។

សារាយ ៖ រឿងស្នេហានេះ ពួកយើងនេះបានមូលមតិគ្នាថា នៅសម័យនេះវាជារឿងបោកបញ្ឆោតទៅហើយ ហើយមានទាំងខសន្យានឹងគ្នាថា ឈប់យករឿងអបមង្គលនេះមកធ្វើជាគោលការណ៍ជជែកវែកពិភាក្សា... ដូចក្មេងអនុវិទ្យាល័យ ឱ្យតែខាតពេលវេលាទៀតហើយ ចុះហេតុម៉េចសង្ហាយកបញ្ហាស្នេហានេះមកវែកញែកធ្វើអ្វីទៀត? តិចលោ... ចិត្តខ្លួននោះវាធាបធេះធ្លួលទៅហើយទេដឹង

ឌីណូ ៖ វរ វរ! លោកតា ភោគផល ចង់បានថៅទួតទេដឹង?

វិច្ឆិ ៖ មែនណា៎ សង្ហាហោតែចោទរឿងស្នេហាឡើងវិញ អារឿងចាស់ ដែលយុវជនធន់ពួកយើងធ្លាប់ហែលបឺបួនភ្លើង លែងនឹកនាដល់ទៅហើយនោះ។

ច្រើនគ្នា ៖ មើលបំភ្លឺរឿងហ្នឹងមើល

សង្ហា ៖ អីយ៉ា! យប់នេះ សមាជិកចោទប្រធានហើយ ក្រែងទាំងអស់គ្នាលើកខ្ញុំឱ្យធ្វើជាប្រធានក្រុមមិនជឿឬ? ដែលតាំងខ្ញុំជាប្រធានបែបនេះ ព្រោះតែជឿថា បក្សស្នេហាលែងបញ្ឆោតលួងលោមឱ្យខ្ញុំលង់ក្នុងអន្ទាក់ស្នេហាបានទៀតហើយ ឥឡូវស្រាប់តែមកសង្ស័យលើឯងដែរ ដែលជឿច្បាស់ថា ស្នេហាបរិសុទ្ធ ស្នេហាចិត្តមួយនិងមួយ ស្នេហាទុំទាវ នៅសតវត្សនេះ លែងមានទៀតហើយ សតវត្សនេះមានតែស្នេហាបង្ខំ ស្នេហាព្រោះចង់ចំណេញទឹកប្រាក់ ស្នេហាមិនមែនពីព្រោះស្នេហា តែពីព្រោះបញ្ហាក្រៅពីស្នេហា ស្នេហាដឹកញីប្រសុីឈ្មោល...។

ប៉ូល ៖ សើចខ្លាំង គេមើលលាន់ អាពួកម៉ាកខ្ញុំម្នាក់នោះ ប៉ាម៉ាក់វាចាប់ឱ្យការជាមួយនឹងកូនថៅកែម្នាក់ រួចវាស្រឡាញ់នាងម្នាក់នោះទៅហើយកូនថៅកែនោះថាស្រឡាញ់ស្មៀនថៅកែនោះដែរ តែមិនដឹងជាយ៉ាងម៉េចទេ ចុងក្រោយបំផុត អាពួកម៉ាកខ្ញុំការជាមួយកូនថៅកែនោះទៅ ឥឡូវប្រពន្ធវាពោះស្អុយទៅហើយ។

តារា ៖ ទារកដែលនឹងកើតមក កើតទាំងបង្ខំ។ សើច។

លិនដា ៖ មិនសើច ស្រងូតស្រងាត់។ រឿងកំសត់ទៅជាសើច ខ្ញុំថាកំសត់ព្រោះសង្សារខ្ញុំនេះឯង ត្រូវប៉ាម៉ាក់គេបង្ខំឱ្យការជាមួយកូនថៅកែម្រេចបាត់ទៅ...

សារាយ ៖ រឿងលិនដាឯងកំសត់ណាស់ហ្ន៎...

សង្ហា ៖ មិនមែនតែរឿងលិនដាទេ នៅសតវត្សបរមាណូនេះ ជារឿងរបស់យុវជនទាំងអស់ ប្រុសៗសុទ្ធតែទៅជាប្ដី ស្រីៗសុទ្ធតែទៅជាប្រពន្ធ នឹងបុគ្គលដែលខ្លួនមិនស្រឡាញ់ ម៉្លោះហើយបើយើងធ្មេចភ្នែក ហើយបណ្ដោយឱ្យខ្សែអារម្មណ៍ យើងឆ្លុះមើលទៅមនុស្សគ្រប់គ្នា ឃើញខ្សែជរនៃចិត្តចេញពីផ្ទះនីមួយៗចេញពីបន្ទប់ ចេញពីមុង ទៅរកផ្ទះ ទៅរកបន្ទប់ ទៅរកមុងដទៃ ព្រោះគូស្នេហាច្រើនតែបាក់បែកគ្នាទៅទីដទៃរៀងខ្លួន។

ឌីណា ៖ យី! ករីចេះស្រដីយ៉ាងពីរោះក្បោះក្បាយពីអភ័ព្វស្នេហាផង...

សារាយ ៖ ឃើញទេពួកយើងថាកុំឱ្យយកស្នេហាមកនិយាយវិលទៅវិលមកជុំតែវិញ បញ្ហាស្នេហានេះ។

សង្ហា ៖ មនុស្សលោកបែកបាក់គ្នា មិនស្រឡាញ់គ្នា សង្កៀតធ្មេញដាក់គ្នា ប្រទូសរ៉ាយចង់ធ្វើសង្គ្រាមសម្លាប់គ្នា ព្រោះតែមនុស្សជាតិ

សម័យឥឡូវមិនបានចាប់បដិសន្ធិក្នុងគភ៌ ដែលជាសំបុកកើតឡើងដោយស្នេហា។

**រិទ្ធី ៖** ងាប់ហើយ កាន់តែវែងទៅវែងទៅ ឃ្លាតចាកពីសេចក្ដីណាត់របស់យើង ដែលថាចង់ធ្វើយុវជនមួយក្រុមរស់ទៅតាមសតវត្សបរមាណូ គឺបណ្ដែតបណ្ដោយខ្លួនឱ្យអណ្ដែតទៅតាមពេល ដោយពុំព្រមយកខួរក្បាលទៅឱ្យជំពាក់នឹងបញ្ហាស្មុគស្មាញអ្វីទាំងអស់ រស់ក្នុងភ្លេង រស់ក្នុងចម្រៀង រស់ក្នុងសប្បាយ រស់ក្នុងសប្បាយជានិច្ច...។

## សួរមាន់រងារ

**សង្ហា ៖** កវីជាច្រើន បញ្ឆោតយុវជនថាសំឡេងទាំងនេះពីព្រោះថាមានទឹកដម ថាខ្យល់ជំនោរជាដង្ហើមទឹក ផ្សាយក្លិនក្រអូប មកអង្អែល យានិន្ទ្រិយារម្មណ៍ ថាទឹកសន្សើមដែលជាប់នឹងស្មៅសុទ្ធតែគ្រាប់ពេជ្រមកដាក់លើពសុធា យើ!កវី កវីអស់ហ្នឹងដល់តែម្ដង អាងតែខ្លួនចេះសរសេរ បញ្ឆោតគេឯងឱ្យជឿស្លុង ឱ្យលង់ខ្លួនតាមគាត់ នែ! បើឃើញថ្ងៃក្រហមដូចឥឡូវនេះ ច្បាស់ជាគាត់ថា ៖ ឱ! សុរិយាអើយរង់ចាំអីទៀត នឹងបន្លឺមព្រះកេសាឱ្យផុតពីកម្ពីក្រហម ដើម្បីមកបំភ្លឺផែនពសុធា... គ្រាន់តែថ្ងៃរះប៉ុណ្ណឹង ព្រោកប្រាជ្ញឱ្យឯងហ្នឹងពិបាកតែធ្វើប្រឡងត្រីមាស ដោយសារតែគាត់។

លិនដា ៖ មែន! នែ! អង្គុយលេងៗ មួយយប់កន្លងផុត លេងៗមួយថ្ងៃកន្លងផុត១ខែ ១ឆ្នាំ ១០ឆ្នាំ តាំងរករណ្តៅរៀងខ្លួនហើយណា... ណ្ហើយ មុននឹងរករណ្តៅច្រៀងឱ្យវាណាណីសិន ទាន់ខ្លួននៅក្មេង។ ទាំងអស់គ្នារាំ ច្រៀង សប្បាយ...

(មីងផៃស្ទាបហ៊ម កាន់អំបោសចូលមក ការប្រទះគ្នា នាំឱ្យស្រឡាំងកាំងមួយភ្លែត)។

ផៃ ៖ យី! ងាប់ហើយ អ្នកនាងមួយយប់ទាល់ភ្លឺតែម្តង កំលោះក្រមុំអី អ៊ីចឹងមិនគិតទៅផ្ទះទៅសម្បែងធ្វើការធ្វើងារអីទេ លោកតាមកវិញ ជេរខ្ញុំងាប់ហើយ។

សង្ហា ៖ ម៉ែផៃ! បើស្រឡាញ់ខ្ញុំត្រូវទុកឱ្យខ្ញុំសប្បាយតាមចិត្ត។

ផៃ ៖ សប្បាយវាមានពេលវេលាដែរ ពេលខ្លះគេធ្វើការ ពេលខ្លះគេរៀន ពេលខ្លះគេសប្បាយ ចុះបើយើងសប្បាយមិនឈប់ឈរនោះអាសប្បាយបែបនេះវាទៅជាធុញទៅវិញទេណា។

សង្ហា ៖ ធ្វើការរកស៊ីព្រោះចង់បានលុយ ចុះបើសម្បត្តិលោកតាខ្ញុំចាយមិនអស់ ហើយខ្ញុំជាចៅតែមួយរបស់គាត់ ឱ្យខ្ញុំធ្វើការរកស៊ីធ្វើអីទៀត?

ផៃ ៖ ចាំមើលតែបានប្រពន្ធទៅឈប់និយាយអ៊ីចឹងហើយ

សារាយ ៖ បានប្រពន្ធ

ប៉ូល ៖ មីង! ថាម៉េច ប្រពន្ធ?

តារ៉ា ៖ សង្ហា ប្រពន្ធ

ឌីណូ ៖ ប្រពន្ធ

លិនដា ៖ មើល! ល្អមើលមែន ប្រពន្ធ

ផៃ ៖ អើ! អាណាទុកឱ្យអ្នកនៅអ៊ីចឹងមួយអាយុ លោកតាទៅបាត់ប៉ុន្មានថ្ងៃនេះ គាត់ទៅរកលុយគេឯង នឹងរកស៊ើបដណ្ដឹងប្រពន្ធឱ្យអ្នកហើយណា។

## ទាំងអស់គ្នាសើច

សង្ហា ៖ ម៉ែផៃ! យប់មិញយល់សប្ដិមិនស្រួលហើយឬជាយល់សូងទេដឹង ឮពួកយើងចោទពីបញ្ហាហ្នឹង ព្រលឹមឡើងផ្លូងឯងភ្លាមតែម្ដង។

ផៃ ៖ ចំណាស់មីងហើយ មុននឹងដេកភាវនាធម៌គ្មានយល់សប្ដិយល់សូងអី ដូចកំលោះក្រមុំទាំងអស់ទៀតទេ តែមីងថាអីម៉េចទេ អ៊ីចឹងហើយមានសម្បត្តិប៉ុណ្ណឹងអាយុ២២ឆ្នាំហើយចាំអីទៀតនឹងរកគូស្រករ។

សង្ហា ៖ ថាម៉ែផៃ ថាជាតិនេះខ្ញុំមិនយកប្រពន្ធទេ ពួកយើងនេះ

គ្មាននរណាយកប្ដី យកប្រពន្ធទេ។

ផៃ ៖ ចុះពួកហ្នឹង វាកើតអីបានជាមិនយកប្ដីយកប្រពន្ធ វាកើតឃ្លង់ឬ?

ប៉ូល ៖ (បង្ហាញជបស្រា)នេះប្រពន្ធខ្ញុំ

រិទ្ធី ៖ លេងភ្លេងទូសមួយបទ នេះប្រពន្ធខ្ញុំ

ផៃ ៖ ភ្លេងញាក់ទទ្រើតអ៊ីចឹងមិនចេះស្ដាប់ទេ

សារាយ ៖ មើលមុខខ្ញុំឱ្យច្បាស់ផង មិនមែនកើតឃ្លង់ទេណា។

ផៃ ៖ ចុះម៉េចក៏មិនយកប្ដី ប្រុសៗម៉េចមិនយកប្រពន្ធ។

សន្លា ៖ ម៉ែផៃ! ស្រីណាម្នាក់ដែលមានសម្លាកដៃ ហើយឧស្សាហ៍បង្ហាញខ្ញុំថានែ...នេះស្នាមប្ដីចាក់នឹងកាំបិតកែ ក្រែងម៉ែផៃឯងឬ?...ដែលផ្ទៃពោះកូនដំបូង ហើយពូផង់គាត់វក់នឹងស្រីឡាំថូនដើរចោលមីងឯង មីងឯងទៅតាម ឃើញគាត់កំពុងរាំធ្វើឆោទ្បោដាក់គាត់ គាត់ចាក់មួយកាំបិតត្រូវដៃ ភ័យអាសន្នរហូតដល់បាត់បង់ទារកក្នុងគភ៌ បង្ហូរទឹកភ្នែកតាំងពីនោះមក ខ្ញុំដឹងក្ដីកាលណានិយាយប្រាប់ខ្ញុំកាលនោះ ឥឡូវមកប្ដីប្រពន្ធអីទៀត។ មើលស្នាមដៃរំឭកមើលវាប្រាប់ម៉ែផៃឯងថាម៉េចខ្លះ?

ផៃ ៖ ថាមីងបានយំ បានបង្ហូរទឹកភ្នែកជូតក្បាលជង្គង់ជាង២០ឆ្នាំ មុននឹងរកពន្លឺព្រះធម៌ឃើញតែមីងមិនស្តាយទេ ព្រោះមីងបានស្គាល់សេចក្តីស្នេហាដែរ

សង្ហា ៖ ទុក្ខនៃសេចក្តីស្នេហា ស្គាល់ទុក្ខនៃសេចក្តីស្នេហាដែរហា?

ផៃ ៖ ទុក្ខ... មែនជាទុក្ខ វាជាអំបិលជាប្រហុក ដែលបង់សម្លជីវិតកុំឱ្យវាភ្លាវ កុំឱ្យវាសាប អ្នកទាំងអស់គ្នាសើចឡឡៀឡឡ ដូចជាគ្មានសប្បាយសោះជីវិតសាបរលែម។

ប៉ូល ៖ ព្រោះតែសាបហើយបានជាគេដាក់ពីបីដូស

រិទ្ធី ៖ លេងមិនបានទេម៉ែផៃ គាត់ចង់បញ្ចេញមនោគមន៍វិជ្ជាជាជីវិតមួយផ្នែកទៅទៀត

ផៃ ៖ នែ! ទៅ ខ្ញុំគ្មានបញ្ចេញបញ្ចូលអីទេ ទៅផ្ទះសំបែងទៅលោកតាមកដេរខ្ញុំស្លាប់ហើយ អាណាចេះមកលេងផ្ទះគេមួយយប់ទើសក្លីអីចឹង ថ្ងៃរះហើយទៅ ទៅធ្វើការងារទៅ។

សារាយ ៖ ទៅឥឡូវហើយ តែសុំមើលសម្លាកដៃបន្តិចមើល

តារា ៖ ម៉េចសារាយចង់បានសម្លាកអីចឹងដែរឬ?

ឌីណូ ៖ ការពិតសម្លាកដៃបែបនេះមានតម្លៃខ្លះដែរមើលទៅ

ផៃ ៖ វាទៅជាយកសម្លាកឯងបំបែកសេចក្ដីឯណាឯណោះទៅវិញទៀតហើយ ទៅ! ទៅ...។

## សូរសញ្ញារថយន្ត

មីជ័ផៃ ៖ នុំះ! លោកតាមកហើយ

ប៉ូល ៖ ទៅពួកយើងទៅ លោកតាហ្នឹងមិនបានទេ វរ វរ ត្រូវខ្មោងរបស់គាត់។

សង្ហា ៖ ពួកយើងទ្វារក្រោយ តាគ្នាលេងពុំបានទេ វរ វរ ផ្ដាច់សោហ៊ុយគ្នាអស់ឥឡូវ ចាស់គាត់នេះជាចាស់សម័យអង្គរណា។

## ទាំងអស់គ្នាចេញតាមទ្វារក្រោយ

ចូលមក ៖ ឃី! កាផៃអើយ អញមិននៅប៉ុន្មានថ្ងៃ ស្អីអីចេះ។

ផៃ ៖ លោកចៅបណ្ដូលចិត្តណា...

តា ៖ ចុះឥឡូវវាទៅណាទៅហើយ?

ផៃ ៖ មួយយប់ទាល់ភ្លឺនៅទីនេះ អារាំញាក់ស្ទន់ជាន់បែបណាក៏ឃើញអស់ហើយ ប្រុសស្រីកៀកគ្នាបែបម៉េចក៏ឃើញអស់ដែរ មួយយប់ទាល់ភ្លឺ ទើបតែនឹងឮឡានលោកតាមកបានប្រាយអស់នៅអម្បាញ់មិញ ខ្ញុំនិយាយថាឱ្យយ៉ាងម៉េចក៏មិនញ៉ើនដែរ គេថា គេកើតមកហើយ

ត្រូវសប្បាយ សប្បាយ សប្បាយ ហើយចម្លែកណាស់ទៅទៀត គេថា គេមិនព្រមយកប្រពន្ធទេ

តា ៖ អូមែន ផៃ អញភ្លេចនិយាយប្រាប់ ស្រេចការអស់ហើយ រឿងហ្នឹង

ផៃ ៖ ស្រេចការអស់ហើយរឿងហ្នឹង

តា ៖ រឿងកូនស្រីអ្នកទ្រលុកនោះណា

ផៃ ៖ កូនស្រីអ្នកទ្រលុកនៅឧត្តុង្គ

តា ៖ ហ្នឹងហើយកាផៃ! អញប្រាប់ឯងមុនឱ្យហើយទៅចុះ អ្នកស្រីទ្រលុកគេព្រមទុកដាក់កូនស្រីគេ នាងសូភីឱ្យមកអាសង្ហាហើយ។ អ្នកទ្រលុកមានពេជ្ររាប់រយ មានមាសរាប់នាទ្បិសមនឹងសម្បត្តិស្តុកស្តម្ភអញដែរ។ ហាងឯងដូចមិនអបអរសោះ...

ផៃ ៖ ក្រែងគ្នាយើងនេះគេមិនចូលដៃជាមួយ គេសុទ្ធតែប្រកាសថា គេមិនជឿលើសេចក្តីស្នេហាទេ ហើយបើគ្មានសេចក្តីស្នេហា គេមិនអាចរួមរស់ជាមួយគ្នាធ្វើជាប្តីប្រពន្ធកើតទេ គេនេះជាពួកមិនចាញ់បោកជីវិត ហើយទទួលរស់នៅក្នុងជីវិតនេះជាមនុស្សដកខ្លួនផុតពីសេចក្តីស្នេហា...

តា ៖ ព្រឹកនេះអី ក៏ហូរហែម៉េះកាផៃ ?

ផៃ ៖ ចុះបើជជែកបែកពពុះមាត់មួយភ្លើងពីរភ្លើងទៅហើយតាំងពីព្រហាម រួមសេចក្ដីទៅគេថា គេនៅលីវ។

តា ៖ សើច កាផៃអើយ ទៅជជែករកខុសត្រូវជាមួយអាសង្ហានោះវាមិនឈ្នះវាទេ ឯវាចេះតែមានពាក្យដោះសា មានហេតុមានផលពន្យល់ទាំងខុសទាំងត្រូវនោះជានិច្ច ក្មេងឥឡូវគេអួតថា គេមានប្រាជ្ញាប្រាជ្ញាមែនហើយ ប្រាជ្ញាត្រង់ចេះដោះសាពីកំហុសរបស់ខ្លួន ណ្ហើយកុំទៅជជែកជាមួយនឹងវានាំឱ្យខាតពេល។ ឯចឹងហើយបានជាទៅគិតគូរកូនអ្នកទ្រលុកនោះអញលាក់មិនឱ្យវាដឹងបន្ដាក់បន្ដិចទេ អូបើវាដឹងមុន អូព្រោកប្រាជ្ញពន្យល់ឯង ចេញទ្រឹស្ដីពីស្នេហា ពីសេរីភាពក្នុងស្នេហា ពីចំណងស្នេហា ពីស្នេហាបន្លំ ស្នេហាបង្ខំ ស្នេហាចំណេញស្នេហាជំនួញ...អូវែងណាស់ បានថា អញទៅគិតគូរនឹងចាស់ៗស្រេចដឹងសម្ដីគ្នា ចាប់វាភ្ជួល់គ្នា ឯណាបើមិនហែងបាត់មាត់ចុក។ នែ! សូភីជាកញ្ញាមួយរូបដូចសំពត់ក្នុងផ្នត់ លុះដំបូន្មានម្ដាយគេ ស្គាល់ចាស់ស្គាល់ទុំ ច្បាស់ជាឃើតឃោងអាសង្ហាឃើងឱ្យផុតពីររបៀបរស់នៅដូចវាសព្វថ្ងៃនេះបាន។

ផៃ ៖ មានអីទៀតឱ្យតែគេព្រមការ

តា ៖ ព្រមមិនព្រម ដល់ហែងទាល់តែព្រម

ផៃ ៖ ចុះបើគេមិនព្រមទៅផល់ ទៅជួបផងនោះ។

តា ៖ មិនព្រមកាត់កាល់ហែងចោល

ផៃ ៖ ឈប់និយាយពីកាត់កាល់ទៅ លោកតាឯងថា តែកាត់កាល់កាត់កាល់ តែវាគ្មានទៅជាខ្មែះអីទេ

តា ៖ អើ! បើកាត់កាល់មែនទែនមិនកើត ក៏អញកាត់ចំណាយវាដែរ

ផៃ ៖ ទទៀតហើយ កាត់ចំណាយ កាត់ចំណាយ ថាកាត់ណាស់ណាស់ទៅចំណាយកាន់តែឡើងឡើង

តា ៖ អើវី! និយាយពីចំណាយដូចជាមានសំបុត្រយកលុយវិក្កយបត្រ ផ្ញើមកនេះច្រើនណាស់។

## ពេលនោះសង្ហាដើរចូលមក

តា ៖ ឯងទើបនឹងមកពីណាអាសង្ហា ស្អីអញសួរមិនស្តី

សង្ហា ៖ ចុះម៉ែផៃរាយការណ៍ជម្រាបសព្វគ្រប់អស់ហើយចាំបាច់សួរខ្ញុំធ្វើអីទៀត

តា ៖ ការផៃទៅរកបបរមកអញស៊ី ព្រឹកនេះមានការនិយាយសង្ហានៅហ្នឹងសិនហើយអង្គុយទៅ

សង្ហា ៖ មើលទៅវែងហើយ បានជាឈរស្តាប់មិនបានតោង អង្គុយ។ អង្គុយក៏អង្គុយ។

តា ៖ រួចស្អី! ពីរពាន់រៀល ម៉ុងឌីយ៉ាល់

សង្ហា ៖ បាយម៉ែផែមិនឆ្ងាញ់ ខ្ញុំទៅញ៉ាំបាយអាម៉ុងឌីយ៉ាល់ទៅ

តា ៖ ចុះអាតាន់យៀកប៉ុន្មានសម្រាប់

សង្ហា ៖ ប៉ុន្មាន មួយសម្រាប់

តា ៖ ម៉េចក៏ក្នុងវិក្កយបត្រវាដាក់ថា៥សម្រាប់

សង្ហា ៖ អូមែន ខ្ញុំជូនប៉ូល តារា រិទ្ធី ទីណូ ម្នាក់មួយសម្រាប់។

តាកំហាក ៖ អាសង្ហា ហែងជាចៅអញ ពួកអាអស់នោះមិនមែនជាចៅអញទេ ហែងបំផ្លាញអញក៏បំផ្លាញម្ល៉េះ។ សង្ហាស្ទុះចេញ។ ឈប់សិនកុំអាលទៅណា ចុះស្អីឡេឌីម៉ូតស្អី ខោអាវស្រីប៉ុន្មានសម្រាប់ដែរ សង្សារហែងឯណា ប្រពន្ធហែងឯណា?

សង្ហា ៖ សូមជម្រាបលោកតាម្តងទៀតជាចុងបង្ហើយខ្ញុំជាប្រុសយុវជនបរមាណូ គ្មានសង្សារ ហើយមិនព្រមយកប្រពន្ធទេ

តា ៖ ហែងមិនយកប្រពន្ធ

សង្ហា ៖ បាទខ្ញុំមិនយកប្រពន្ធ

តា ៖ អង្គុយសិនទៅអាសង្ហា ណ្ហើយអញឈប់និយាយពីរឿង វិក្កយបត្រ រឿងលុយកាក់ទាំងអស់ អង្គុយទៅចៅចាំតានិយាយ

សង្ហា ៖ បើមានប្រសាសន៍ឱ្យស្រួលដូច្នេះមានអី សព្វថ្ងៃខ្ញុំមាននរណាក្រៅពីលោកតាដែលខ្ញុំស្រឡាញ់

តា ៖ បើស្រឡាញ់តោងតាមអញ

សង្ហា ៖ ខ្ញុំតាមជានិច្ច

តា ៖ បើតាម តោងគិតគូរយកប្រពន្ធ

សង្ហា ៖ សើចយ៉ាងខ្លាំង ចុះយ៉ាងម៉េចបានជារឿងប្រពន្ធហ្នឹងវាចោទយ៉ាងខ្លាំងម៉េះ មើលជីតានឹងចៅប្តូរយោបល់គ្នាពីរឿងបញ្ហាប្រពន្ធនេះម្តងមើល

តា ៖ ព្រះពុទ្ធជាម្ចាស់សំដែងថា មាតុភរិយា មិត្តភរិយា កនិដ្ឋាភរិយា ទាសភរិយា

សង្ហា ៖ លោកតា! លោកតា! លោកតា! សូមទោសយកព្រះពុទ្ធមកលាយឡំក្នុងរឿងគគ្រិច របស់មនុស្សលោកច្រឬកច្របល់ក្នុងកាម ក្នុងរឿងប្រពន្ធកូន រឿងគ្រួសារ គ្រួសារប្តីប្រពន្ធឈ្លោះគ្នា ប្រចែប្រចណ្ឌគ្នា លះលែងគ្នា រីឯរឿងស្រីដែលឥតទីពឹង លក់ខ្លួនធ្វើជារបរនោះ ខ្ញុំមិនបាច់រំលឹកក្នុងពេលនេះទេ ។ ឥឡូវលោកតានេះ នៅសុខសុខចង់កៀងខ្ញុំឱ្យចូលក្នុងអន្ទាក់នេះ ឱ្យខ្ញុំភ្ជាប់ជីវិតខ្ញុំទៅនឹងអ្នកម្នាក់ទៀត

ហើយសំខាន់បំផុត អ្នកម្នាក់នោះដែលថានឹងមករួមជីវិតជាមួយខ្ញុំនោះ ខ្ញុំមិនស្គាល់មិនដឹងចិត្តគេយ៉ាងម៉េចផង។

តា ៖ យី! នាងសូភីកូនអ្នកទ្រលុកមានពេជ្ររាប់រយគ្រាប់ មាសរាប់នាឡិ

សង្ហា ៖ ន៎ុះ! ឃើញទេ លោកតាយកខ្ញុំទៅលក់ហើយតើ

តា ៖ យី! អញមិនលក់ហែងទេ អញរកប្រពន្ធឱ្យ

សង្ហា ៖ មិនឮនិយាយពីប្រពន្ធសោះ ឮតែនិយាយពីពេជ្រមាស

តា ៖ អូ! ចៅចង់ដឹងពីនាងហ្នឹងឬ? ឈ្មោះនាងសូភី ជាឈ្មោះផ្កាដ៏មានក្លិនក្រអូប មុខមូលដូចព្រះចន្ទ ចិញ្ចើមខ្វង់ដូចឥន្ទធនូ រាងរៀវចង្កេះអង្រ្គង សាច់ស្អាតដូចមាក់ប្រាង...

សង្ហា ៖ គឺថា ល្អផុតផែនដី

តា ៖ កញ្ញាលោកីយរកដូចគ្មាន

សង្ហា ៖ តែគេមិនស្គាល់ខ្ញុំសោះ ខ្ញុំមិនស្គាល់គេសោះឥតស្រឡាញ់គ្នាសោះ ដល់ទៅជាប្តីប្រពន្ធទៅតាំងមិនស្រួលនឹងគ្នាមួយថ្ងៃបន្តិច។ ហើយដើម្បីកុំឱ្យខូចកិត្តិយសគ្រួសារកុំឱ្យខូចសម្បត្តិទ្រព្យដោយអាណិតកូន ឪពុកម្តាយ ជីដូនជីតា មាមីង ក៏ទ្រាំរស់នៅជាមួយគ្នាទាំងទុក្ខ ដូចរឿងគ្រួសារទាំងឡាយដែលលោកតានឹងម៉ែផៃ ដែលប្រលោមលោកនឹងខ្សែភាពយន្តតែងតែនិទានមិនអស់មិនហើយ។

តា ៖ ស្រីណាអញមិនហ៊ានថាទេ តែនាងសុភីច្បាស់ជាមាន គំនិតមារយាទ ចរិយាជាស្រីគ្រប់លក្ខណ៍ ចេះស្រឡាញ់ ប្រុសរបស់ខ្លួន

សង្ហា ៖ អូ! ទុកចិត្តមិនបានទេ ខ្ញុំធ្លាប់ដើរលេងស្គាល់ស្រីៗ អស់ហើយ សុភី ស្អីក៏ ដោយក៏ទុកចិត្តមិនបានដែរ ស្រីសម័យនេះចិត្ត សាវ៉ា ចិត្តរាយមាយ ចិត្តពីរបី ចិត្តមួយរយ។

តា ៖ នែ! ហែងកុំថាអីចឹងឱ្យសុភីណា

សង្ហា ៖ ស្អីលោកតា ក៏កាន់ជើងសុភីទៅហើយ គេមិនទាន់មក ជាចៅប្រសាផង

តា ៖ សុភីគេមិនសូវដូចស្រីផងទាំងឡាយដែលហែងធ្លាប់ស្គាល់ នោះទេ សំពត់ក្នុងផ្នត់ណា ស្ដាប់អញឱ្យបានសំពត់ក្នុងផ្នត់

សង្ហា ៖ សំពត់ក្នុងផ្នត់ តែលាទៅត្រូវភ្លៀងត្រូវថ្ងៃហើរពណ៌ ជាងអាសំពត់ដែលគេធ្លាប់ហាលភ្លៀង ហាលថ្ងៃ ពីដើមស្រាប់ទៅទៀត។ លោកតាស្ដាប់ខ្ញុំមែនទែន លោកតាអួតថានាងសុភីនេះល្អ ព្រហ្មចារី ខ្ញុំជឿហើយ តែក្រែងមកពីនាងនេះពុំទាន់មានឱកាសប៉ះពាល់នឹងជីវិត ស្គាល់ប្រុសៗនោះទេដឹង នែ! ជួនកាលដល់លែងពីទ្រុងទៅ ស្រីបែបនេះ ត្រឡប់ទៅជាខិលខូចជាងនារីដែលមានការពិសោធក្នុងជីវិតទៅទៀត។

តា ៖ ណ្ហើយ ដល់ទ្រឹស្ដីអប់រំស្ត្រីទៀតហើយ

សង្ហា ៖ ចុះលោកតា មានប្រសាសន៍ថា ឱ្យខ្ញុំបង្ហាញចិត្តខ្ញុំឱ្យត្រង់ក្នុងរឿងប្រពន្ធកូន លោកតាខ្ញុំមិនចង់បានប្រពន្ធមកហើយ គេមិនស្រឡាញ់ខ្ញុំនោះទេ តែព្រោះតែកិត្តិយសគេ ត្រូវតែរស់ជាប្រពន្ធមានភក្តីជាមួយខ្ញុំ។ ក្នុងករណីនេះ ខ្ញុំនឹងទៅជាប្រុសម្នាក់បំផ្លាញជីវិតនារីម្នាក់ក្នុងករណីដែលនាងនោះបែកចិត្តពីខ្ញុំដើរអាវាសែ ខ្ញុំនឹងទៅជាមនុស្សប្រុសម្នាក់ដែលមានប្រពន្ធជាស្រីមិនប្រកបដោយគន្លងធម៌ ឃើញទេផ្លូវដោះស្រាយមានតែមួយគឺកុំយកប្រពន្ធ

តា ៖ បើមនុស្សទាំងអស់ក្នុងលោកនេះ គិតដូចតែហែង មួយរយឆ្នាំមនុស្សជាតិរលត់ឈឹង

សង្ហា ៖ ជាការស្រាយបញ្ហាមួយដែរ?

តា ៖ អញថាហើយថា ហែងនេះតែព្រមជជែកជាមួយនិយាយមិនឈ្នះហែងទេ ឥឡូវអញនិយាយតែខ្លី តើព្រមការជាមួយសូភីឬទេ? ឆ្លើយមក ព្រមឬទេ? ខាងស្រីអ្នកទ្រលុកគេព្រមហើយ ហែងថាម៉េច។

សង្ហា ៖ ចុះសូភីអីគេហ្នឹង គេថាម៉េចដែរ?

តា ៖ គេមានថាម៉េច កូនស្រីគេមានពូជ គេមិនរឹងត្អឹងដូចក្បាលអាឯងទេ គេ ម៉ែគេថាម៉េច គេតាមម៉ែគេហើយ។

សង្ហា ៖ ខាងផ្លូវជជែកលោកតាពូកែណាស់ដែរ បង្វែរពាក្យបញ្ចៀសសេចក្ដីមិនឆ្លើយឱ្យចំសំណួរខ្ញុំទេ

ខ្ញុំសួរថា នាងសូភីព្រមទទួលយកឈ្មោះភោគផលសង្ហា ដែលនាងពុំដែលស្គាល់ ពុំដែលទាំងឮឈ្មោះបោះសំឡេងផងនោះ ធ្វើជាប្ដីឬទេ? បែបអ្នកទ្រលុកមិនទាំងសួរគ្នាផងមើលទៅ មិនទាំងឱ្យគ្នាដឹងមុនផងទេមើលទៅ ដឹងជាចិត្តនាងនោះយ៉ាងណា! ផ្ដួលទៅលើបុរសណាមួយទៅហើយទេដឹង។

តា ៖ កុំនិយាយឆ្កួត កូនគេគ្រប់លក្ខណ៍គេមិនទាន់ទាក់ទងនឹងប្រុសទេ

សង្ហា ៖ ប្រលោមលោក ប្រលោមលោករូបភាព ចម្រៀងស្នេហាភាពយន្ត ល្ខោន ច្រើនណាស់លោកតា យើងឥឡូវនេះទប់ចិត្តស្រីមិនឱ្យអណ្ដែតមិនបានទេ

តា ៖ កុំនិយាយឆ្កួត

សង្ហា ៖ បើមិនឱ្យនិយាយ ឆ្លើយខ្ញុំមក តើនាងសូភីព្រមស្រលាញ់ខ្ញុំទេ?

តា ៖ គេព្រម

សង្ហា ៖ ព្រម

តា ៖ អើ! ព្រម

សង្ហា ៖ សើច! មិនទាំងស្គាល់មុខមាត់ ឈ្មោះ សំឡេងខ្ញុំសោះ ស្រាប់តែនាងសូភីព្រមស្រលាញ់ភោគផលសង្ហាទៅហើយ លោកអើយ ជួយស្តាប់ចុះ ហើយគេថាជាស្រីគ្រប់លក្ខណ៍ផង ព្រោះព្រមស្រលាញ់ប្រុសដែលពុំដែលស្គាល់ រីឯស្រីណាដែលស្រឡាញ់ប្រុស ដែលបានស្គាល់ត្រឡប់ទៅជាស្រីខាតលក្ខណ៍ទៅវិញ

តា ៖ សូភីមិនបានស្គាល់ក្បាលអាឯងមែន តែអ្នកទ្រលុកគេស្គាល់អញ

សង្ហា ៖ ឱ្យអ្នកទ្រលុកហ្នឹងការជាមួយលោកតាទៅ

តា ៖ យី! វាយក្បាលអាអំបែងក្បាលហ្នឹងម្តង។

សង្ហា ៖ ឮតែវាយក្បាល ខ្ញុំដុសគំនិតថ្មីមួយ ហើយខ្ញុំជឿថា គំនិតថ្មីនេះ លោកតាក៏នឹងយល់ស្របមិនខាន។ លោកតាខ្ញុំព្រមរៀបការជាមួយនឹងសូភីហើយ...

តា ៖ ល្អ ល្អ

សង្ហា ៖ កុំអាលសិន គំនិតខ្ញុំមិនទាន់ចប់ទេលោកតា ចង់បានចៅប្រសាដោយគន្លងធម៌ គឺថាសំខាន់បំផុត ប្រពន្ធមានចិត្តភក្តីនឹងប្តី មិនក្បត់ចិត្តប្តី នាងសូភី មិនទាន់ទាំងស្អីផងថាស្រលាញ់ខ្ញុំទៅហើយ

កញ្ញាចិត្តទន់បែបនេះគ្មានការពិសោធក្នុងជីវិត គ្មានធ្លាប់ទាក់ទងទាល់តែសោះជាមួយនឹងប្រុសភេទបែបនេះ យើងទុកចិត្តពុំបានទេ។

តា ៖ ក្រៅពីសូភី អញមិនឱ្យហែងយកអ្នកណាទាំងអស់

សង្ហា ៖ កុំអាលសិនលោកតា ខ្ញុំសូមស្នើធ្វើការពិសោធស្នេហាសម្ងាត់មួយ។

តា ៖ ពិសោធន៍យ៉ាងម៉េច សូភីគេស្រឡាញ់តែអាឯងចៅអញឈ្មោះអាសង្ហា

សង្ហា ៖ នែ! ការពិសោធយើងនៅត្រង់ហ្នឹងហើយ នាងនោះមិនស្គាល់ឈ្មោះខ្ញុំ ខ្ញុំទៅ ល្បងចែចង់នាងដោយមិនប្រាប់ឈ្មោះពិតរបស់ខ្ញុំ។

តា ៖ ទៅ! បើមិនគ្មោងអ្នកទ្រលុក នឹងត្រូវនាងសូភីបញ្ឆោរ

សង្ហា ៖ រឿងនេះជារឿងរបស់ខ្ញុំ សុំលោកតាតែ១៥ថ្ងៃ បើខ្ញុំទៅចង់នាងមិនបាន នាងនោះប្រាកដជាស្រីល្អមែនហើយ លោកតាដណ្ដឹងនាងឱ្យខ្ញុំចុះ ខ្ញុំព្រមយកគេធ្វើប្រពន្ធហើយ ក៏ប៉ុន្តែ ខ្ញុំដែលក្លែងខ្លួនឈ្មោះដទៃទៅចែចង់នាងនោះបានក្នុងរយៈ១៥ថ្ងៃនោះ នឹងសឱ្យឃើញថានាងសូភីមិនមែនសំពត់ក្នុងផ្នត់ល្បើកនោះទេ នឹងយកធ្វើជាអនាគតចៅប្រសាលោកតា ក៏មិនបានដែរ។

តា ៖ ចុះរឿងនេះដណ្ដឹងភ្ជាប់ពាក្យគេជាផ្លូវការនោះឯងគិតយ៉ាងណាទៅ?

សង្ហា ៖ លោកតាពូកែរកកលល្បិចសឹងអី ធ្វើជាទៅជូនពាក្យគេឥឡូវទៅណា បើកឱកាសឱ្យខ្ញុំធ្វើការពិសោធស្នេហានេះសិន

តា ៖ គឺថា ហែងទៅលគេ ដោយមិនប្រាប់ថា ហែងជាចៅអញឈ្មោះអាសង្ហាទេ

សង្ហា ៖ ដាច់ខាតថាទេ ខ្ញុំទៅក្នុងឋានៈជាបុគ្គលម្នាក់ទៀតធម្មតា

តា ៖ សូភីគេមិនដោយអាឯងទេអាអើយ!

សង្ហា ៖ ពេលនោះលោកតាទៅភ្ជាប់ពាក្យគេវិញទៅរៀបការឱ្យអាសង្ហាចៅតាទៅចុះ ចុះ! បើសូភីគេដោយតាមខ្ញុំដែលទៅលនោះ តើយ៉ាងណាទៅវិញ?។

តា ៖ មានតែផែនដីក្រឡាប់ ហើយបើផែនដីក្រឡាប់ហើយអញនឹងទទួលយកសូភីជាចៅប្រសាមិនបានដែរ

សង្ហា ៖ និយាយឱ្យខ្លីការពិសោធស្នេហាយ៉ាងសម្ងាត់យើងមានវគ្គដូចតទៅនេះ ដំបូងលោកតាធ្វើជាទៅជូនពាក្យគេថា អាពាហ៍ពិពាហ៍នោះមានដំណើរពុំកើតទេ រួចមកខ្ញុំដោយមិនចេញឈ្មោះឱ្យចំនោះទៅ

ល្បងចែចង់នាងសូភី ក្នុងរយៈពេល១៥ថ្ងៃ បើមិនបាន លោកតាទៅសុំភ្ជាប់វិញបាន នាងសូភីហ្នឹងមិនទៅជាថៅប្រសារបស់លោកតាទេ ម៉េចលោកតាព្រមឬមិនព្រមពិសោធន៍ស្នេហានេះ

តា ៖ ដោយចង់បាននាងសូភីជាថៅប្រសាដោយជឿថាសូភីនឹងមិនដោយមកតាមអាឯងបន្លំនោះទេ ណ្ហើយអញព្រមតាមទៅចុះ

សង្ហា ៖ លោកតាជាជីតាមួយដែលថៅស្រឡាញ់ស្មើជីវិត

តា ៖ អាសង្ហា! កុំបញ្ឆោរអញ ទៅឱ្យបាត់ពីមុខពីមាត់អញទៅ។ សង្ហា ចេញទៅទទួលផៃលើកបបរចូលមក ផៃអើយឯងតោងទៅឧត្តុង្គមួយភ្លែត

ផៃ ៖ ម៉េចអ្នកសង្ហា គេមិនព្រមទេឬ?

តា ៖ អើវាមិនព្រមទេ ទៅនិយាយជូនពាក្យអ្នកទ្រលុកឱ្យអញផងទៅ ទៅភ្លាមទៅ អ្នកនោះនិយាយច្រើនផង តិចលោកគាត់ផ្សាយជ្រុលពេញតែឧត្តុង្គទៅ។ ហៅអាម៉ូតូឱ្យវាបើកឡានជូនទៅ ផៃចេញទៅ ផៃអើយមកនេះសិន រកពាក្យនិយាយជាមួយអ្នកទ្រលុកឱ្យស្រួលណាជូនពាក្យមែនតែជូនក្នុងក្ដីសង្ឃឹម បើនាងសូភីនោះដោយគន្លងធម៌ណ្ហើយចុះផៃ អញមិនដឹងថាម៉េចទេ លៃតាមតែផៃឯងចេះនិយាយឱ្យស្រួលទៅចុះ គ្រាន់តែផ្ដាំថា ថៃទាំសូភីជាកូនស្រីនោះ កុំអស់សង្ឃឹម។

ផៃ ៖ ថៃទាំសូភីកុំអស់សង្ឃឹម ចម្លែកណាស់ហ្ន៎!។

ផៃដើរចេញទៅ

តា ៖ អាសង្ខាវាកំព្រាម្ដាយ ខ្ញុំមានចៅប្រុសតែមួយបន្ដឹងវាពេកទៅក៏មិនកើត យុវជនមួយជំនាន់ៗរមែងមានយោបល់ប្លែកៗគ្នា។ ចាស់យើងនេះហើយដែលត្រូវតែខំប្រឹងឱ្យយល់ដល់យុវជនផង។

ថ្ងៃនេះជាថ្ងៃឧបោសថសីល ព្រះជាម្ចាស់អើយជួយកុំឱ្យសូភីទន់ចិត្តតាមអាសង្ខា ដើម្បីឱ្យទាំងពីរនេះបានជាគូដូចខ្ញុំប្រាថ្នា។

**វាំងននធ្លាក់**

**ចប់ឈុតទី១នឹងមានតទៅឈុតទី២**

# រឿងពិសោធន៍ស្នេហា

## ឈុតទី២

នៅផ្ទះអ្នកទ្រលុក អ្នកទ្រលុកកំពុងអុជធូបលើកដៃ បង្គំថ្វាយព្រះ នាងទាដោតផ្កានាងនួនចូលមកស្លៀកពាក់ទំនងជាទៅវត្ត។

**ទ្រលុក ៖** ព្រះជាម្ចាស់អើយ សុំឱ្យតែបានសម្រេច

**អ្នកនួន ៖** សម្រេចស្អីអ្នក ធ្វើបុណ្យដូចអ្នកចង់បានអីក៏ព្រះលោកជួយដែរ

**ទ្រលុក ៖** ចាសអញ្ជើញ យីអីក៏ព្រលឹមម៉េះថ្ងៃនេះដល់ពេលទៅវត្តហើយហ្នឹង

**នួន ៖** អើ! មកយកដំណឹងណាយប់មិញឮថាលោកឧកញ៉ាលោកតាភោគផលបានជួបនឹងអ្នក ក្រែងលោកវាមានលាភអី ដល់ចូលមកឃើញអុជធូបហើយពោលថាសុំឱ្យសម្រេចសម្រេចអីហ្នឹង ?

**ទ្រលុក ៖** រឿងសូភីហ្នឹងណា ហ៎ះ អង្គុយសិនទៅអ្នកអើយ សម័យឥឡូវនេះមានកូនស្រីពេញរូប ពេញរាងពិបាកណាស់ ស្រុកគេឥឡូវមិនឱ្យរៀនទៅ គេចោទថាឯងខ្ជប់វាឱ្យនៅល្ងង់ ឱ្យទៅរៀនទៅដូចជាបើកឱកាសឱ្យវាមានការទាក់ទងបានថា យី! ខ្ញុំចិញ្ចឹមកាភីមួយទេ តែពិបាកក្រៃណាពិបាក បានជាដូចអ្នកជ្រាបស្រាប់ខ្ញុំបង្ខាំងវាឱ្យនៅ

តែផ្ទះ តែខ្ញុំរកគេមកបង្រៀនអក្សរដឹកនាំវាដែរ ឱ្យវាចេះមើលសាស្ត្រាច្បាប់ស្រីច្បាប់ប្រុសនឹងគេ តែមិនមែនព្រលែងនាងឯងទៅតែតាមខ្សែស៊ីឌីឡៃប៉ាតណាប៉ាតណី មិនស្គាល់យប់មិនស្គាល់ថ្ងៃនោះទេ។

**ឆ្លង** ៖ ត្រូវហើយអ្នក សុភីជានារីខ្មែរត្រូវយ៉ាង មានប្រាជ្ញាឈ្លាសវៃ មានសំដីសំដៅ មានយោបល់ល្អជាស្រីមានចំណេះ ដែលខ្យល់ទំនើបមិនមកប្រឡាក់ប្រឡូសបានក្លិនក្រអូបនេះវាសាយប្រាសខ្យល់។

**អ្នកទ្រលុក** ៖ មានគេបន្ទោសខ្ញុំច្រើនដែរ ថាបន្តឹងកូនស្រីមើលតែសម័យទុំទាវ គេចង់ឱ្យខ្ញុំបណ្តោយឱ្យវាដើរទៅផ្ទះនេះផ្ទះនោះបាន ខ្ញុំដាច់ខាតថាមិនបានតែម្តងស្រុកឥឡូវទៅជួបមនុស្សមេអណ្តើកមេកន្ធាយទៅមិនខូចការ នៅក្មេងវាដឹងអីខូចតែចាស់ៗជាអ្នកនាំ។

**ឆ្លង** ៖ ត្រូវហើយ ក្មេងត្រូវតែបង្ខាំងវា ដល់វាបានប្តីទៅ ស្រេចនៅប្តីប្រពន្ធគេទៅចុះ។

**ទ្រលុក** ៖ ត្រង់ហ្នឹងក៏គេចោទខ្ញុំទៀត ថាមិនគិតបណ្តោយឱ្យកូនធ្លាប់មានការទាក់ទង ជាមួយនឹងប្រុសបន្តិចទៅទេ តិចលោដល់វាបានសេរីភាពវាទៅ សេរីភាព ត្រឡប់ជាផ្តាសទៅវិញ។

**ឆ្លង** ៖ ចាំបាច់ទាក់ទងអីយើង ស្រីអាដែងមិនទាក់ទងហ្នឹង ហើយដែលមានគេប្រាថ្នាច្រើនណាស់ ទាក់ទងទៅនាំតែអស់តម្លៃ គ្មានអ្នកណាគេមើលមុខផង មើលហះក្នុយស្រីអ្នកអីហ្នឹង មិន... នែ នែ... អាហ្នឹងហើយស៊ីវីឡៃ។

ឪលុក ៖ នួនឯងនិយាយត្រូវ សូភី យកតែមកជូនអ៊ំពិសា

ឆួន ៖ កុំព្រួយពីតែ ពីនំអី

ឪលុក ៖ អូមែន សូភីយកនំមកផង

ឆួន ៖ នែ! ទៅវត្តថ្ងៃនេះគិតទៅទាល់ល្ងាចតែម្តងបាយត្រង់ជាមួយជូនជី ស្តាប់ទេសន៍ រសៀលរួចចាំមកផ្ទះ។

## ពេលនោះនាងសូភីលើកទឹកតែនិងនំចូលមក

ឆួន ៖ ស្រស់ម្លឹងៗបីមិនធ្វើឱ្យគេផ្អើល។

សូភី ៖ ជម្រាបសួរលោកអ៊ំ។ អ្នកម៉ែ! ខ្ញុំកំពុងទន្ទេញច្បាប់ស្រីឱ្យចាំមាត់ ព្រឹកមិញបានភ្ញាក់ពីព្រលឹមថ្វាយបង្គំព្រះ ហើយទៅបេះផ្កាម្លិះឱ្យមីងទាដោតជូនអ្នកម៉ែយកទៅវត្ត។

ឪលុក ៖ ល្អហើយកូនម្តាយ ទៅក្នុងវិញចុះ។

នាងសូភីជម្រាបលាចូលទៅ

ឆួន ៖ ម៉េចទៅរឿងបាឡាត់ស្រុកនោះ

ឪលុក ៖ ទេ មិនកើតការទេ បែបចង់មើលងាយឯងផងថាកូនខ្ញុំនេះវាទន់ភ្លន់វាល្ងើយពេក សម័យឥឡូវគេចង់បានលោកស្រីឱ្យហ៊ឹកហ៊ាក់ជាងនេះ តែនួនអើយ ខ្ញុំមិនចង់ហ៊ាននិយាយទេ ព្រោះគេថាឱ្យលាប់សិន។

ឆ្លូន ៖ ស្អីទៅទ្រលុក។

ទ្រលុក ៖ លោកតាភោគផលណា

ឆ្លូន ៖ ចុះយ៉ាងម៉េច

ទ្រលុក ៖ គាត់មិនមានចៅប្រុសមួយ

ឆ្លូន ៖ រួចគាត់គិត នៃសូភី

ទ្រលុក ៖ អើផ្ទះផ្សារ២០ល្វែង ផ្ទះភូមិគ្រឹះ វីឡា៥ លុយរាប់ការុង ឡានធំតូចប្រើមិនអស់

ឆ្លូន ៖ ចៅប្រុសគាត់ណាមួយ

ទ្រលុក ៖ មិនដែលស្គាល់ទេ ឮតែឈ្មោះថាស្អី... សង្ហាអីនោះ

ឆ្លូន ៖ ចុះគេដែលស្គាល់សូភីទេ

ទ្រលុក ៖ គេក៏មិនដែលស្គាល់សូភី សូភីក៏មិនដែលស្គាល់គេ តែលោកតាភោគផលថារឿងឯណោះស្រេចតែគាត់ឱ្យតែខ្ញុំព្រម ខ្ញុំជម្រាបគាត់ថា រឿងឯណោះស្រេចតែខ្ញុំ ឱ្យតែគាត់ព្រម ឥឡូវយើងទាំងពីរចាស់ចាស់ព្រមគ្នាហើយ សម្រេចការយប់មិញ ណា៎

ឆ្លូន ៖ ខ្ញុំជួយអរណាស់! តើបានប្រាប់សូភី ហើយឬនៅ?

ទ្រលុក ៖ នៅទេ! គួរប្រាប់វាដែរឬ? បានជាខ្ញុំមិនប្រញាប់ប្រញាល់ ព្រោះកូនស្រីមួយនេះដូចអ្នកជ្រាបស្រាប់ថាឱ្យឆ្វេង ឆ្វេង ថាឱ្យស្ដាំ ស្ដាំ។

ឆ្នូន ៖ អើ! គួរប្រាប់គ្នាដែរ ឱ្យគ្នាដឹងផងទៅណា ព្រោះរឿងយកប្ដីជាវាសនាជីវិតរបស់គ្នាទៅហើយ។

ទ្រលុក ៖ អីចឹងមានតែហៅវាមក សូភី សូភី

សូភី ៖ ចាស! ចេញមកកាន់ច្បាប់ស្រីនៅដៃ

ឆ្នូន ៖ ស្អីក្បួយ សៀវភៅអី

សូភី ៖ ចាស! ច្បាប់ស្រីជម្រាបប្រសាសន៍លោកអ៊ំ។

ឆ្នូន ៖ មើលដល់ណាហើយ មើលខ្លាំងៗឱ្យមីងស្ដាប់ផងមើល

ទ្រលុក ៖ មើលទៅកូន កូនមើលដល់ណា មើលតទៅណា

សូភី ៖ ...ព្រមាត់ប្ដីហើយខឹងក្ដៅ ប្រទេចជេរទៅតាមដោយចិត្តភ្នាញ់។ មាក់ងាយមួយទៀតនោះមិញ ត្បិតប្ដីស្រឡាញ់ លូកលប្រឡែង។

មួយបិចចាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តជេរវិញ។

ត្បិតតែយល់គេស្រឡាញ់ សំដីផងមិញគំរោះគំរើយ។

ធ្វើខ្នាញ់បែរចេញព្រងើយ ខេខឹងកន្ដើយក្នក់ភ្នាញ់កិរិយា។

**ទ្រលុកា** ៖ អើនួន! ឃើញទេច្បាប់បុរាណយើងល្អណាស់ ម្ដាយលើកកូនឱ្យមានប្ដីហើយ

**ធា** ៖ យី លើកអ្នកនាងឱ្យមានប្ដី

**ឆ្នួន** ៖ ម្ដេចក្មួយសូភីព្រងើយអីចេះ មិនអរទេឬ?

**សូភី** ៖ ចាស! មិនអរទេ

**ទ្រលុកា** ៖ យី!...

**ឆ្នួន** ៖ ខឹងឬ?

**សូភី** ៖ ចាស! មិនខឹងទេ

**ឆ្នួន** ៖ ចុះយ៉ាងម៉េច?

**សូភី** ៖ ចាស! មានយ៉ាងម៉េច

**ទ្រលុកា** ៖ ម៉ែលើកកូនឱ្យមានប្ដី គេកូនអ្នកមានណាស់ មានផ្ទះថ្ម មានឡាន មានពេជ្រ មានប្រាក់ តើកូនថាម៉េចកូនមាសម្ដាយ?

**សូភី** ៖ កូនមានថាម៉េចអ្នកម៉ែ

**ឆ្នួន** ៖ បើមិនថាអី គេដឹងហើយ តើក្មួយសប្បាយ-អរ ឬភ័យ ឬព្រួយ?

តា ៖ អាណាមិនសប្បាយ មានផ្ទះថ្មផង ឡានផង ពេជ្រផង ប្ដីផង មិនអីចឹងនាងភី ?

សូភី ៖ ចាស! សប្បាយក៏មិនសប្បាយ អរក៏មិនអរ ភ័យក៏មិនភ័យ ទុក្ខក៏មិនទុក្ខ

ដួង ៖ ចុះមើល ក្ដួយព្រមឬមិនព្រម ?

សូភី ៖ ចាស! មានរឿងអីថាមិនព្រម! មានរឿងអីថាព្រម!

ទ្រលុក ៖ ឃើញទេ! ថាស្រេចលើខ្ញុំទេ សូភីនោះខ្ញុំប្រដៅបានបទណាស់ ខ្ញុំថាម៉េចវាអីចឹងហើយ

(តាអាចារ្យចូលមក)

អាចារ្យ ៖ អើ អ្នកអើយ! ដល់ពេលទៅវត្តវាហើយណា ។

ដួង ៖ អូ! លោកអាចារ្យមកហើយ ទៅយើងគិតទៅជាមួយគាត់

ទ្រលុក ៖ អញ្ជើញចូលសិនលោកអាចារ្យ

អាចារ្យ ៖ ចូល

ទ្រលុក ៖ ខ្ញុំមានកិច្ចពឹងលោកអាចារ្យបន្ដិច មុននឹងទៅវត្តនេះ ចង់ឱ្យវាយលេខ មើលខែឆ្នាំឱ្យសូភីនិងគូដណ្ដឹងរបស់គេ ។

អាចារ្យ ៖ ណ្ហើយ អ្នកអើយ! លេខអត្ត វាគ្មានប្រយោជន៍អីទេ ឱ្យតែក្មេងៗវាស្រុះស្រួលនឹងគ្នាទៅ ទុកដាក់វាទៅ វាកវែកកផ្ទាំងទៅ។ រួចម៉េចចៅស្រីឯណោះពេញចិត្តនឹងគូដណ្ដឹងនាងហើយឬ? ម៉េចក៏នៅស្ងៀម ប្រាប់តាមើល!

សូភី ៖ ចាស! នាងខ្ញុំ ខ្ញុំ...ចាសខ្ញុំ! ចាស...

ទ្រលុក ៖ វាមិនទាន់ទាំងស្គាល់ជាអ្នកណាមួយផងលោកអាចារ្យ

អាចារ្យ ៖ រួចអ្នកឱ្យគ្នាទៅគេហើយ?

ទ្រលុក ៖ គេមានផ្ទះ២០ល្វែង ផ្ទះភូមិគ្រឹះ៥ លុយរាប់ការុង។

អាចារ្យ ៖ បើឱ្យទៅគេហើយចាំវាយលេខធ្វើអី

ឆ្លូន ៖ ស្អប់លោកអាចារ្យ គេថាអាគមផ្សំអាយុណា៎

អាចារ្យ ៖ សូភីចៅ! ទៅយកក្ដារឆ្នួន ដីស មក។

សូភីធ្វើតាម

អាចារ្យ ៖ មើលឆ្នាំអី ខែឆ្នាំយ៉ាងម៉េច?

ទ្រលុក ៖ អាភី! វាថោះ ពិសាខ ថ្ងៃសៅរ៍

អាចារ្យ ៖ អូ! ល្អណាស់

ទ្រលុត ៖ គេ ឯណោះឆ្នាំម្សាញ់ ខែបុស្ស ថ្ងៃអង្គារ

អាចារ្យ ៖ អូ! ល្អណាស់... ទៅ... បើអ្នកឱ្យទៅគេហើយ ល្អទៅហើយ

ឆ្នួន ៖ លេខអីក៏រហ័សម្លេះ ល្អភ្លាម

អាចារ្យ ៖ ចុះបើ ខាងប្រុស នែ នែ! ផ្ទះ២០ល្វែង ផ្ទះភូមិគ្រឹះ៥ លុយរាប់បាវ ឱ្យគេរហ័ស លេខក៏រហ័ស ល្អហើយ ល្អហើយ សមហើយ គូគ្នាហើយ

## ពេលនោះមីងផៃចូលមក

ផៃ ៖ ជម្រាបសួរ អ្នក!... លោកអាចារ្យ

អាចារ្យ ៖ សមហើយ ល្អហើយ ត្រូវហើយ ការទៅ

ទ្រលុត ៖ ឃើញទេផៃ លេខក៏ឆ្លើយអីចឹង ម៉េចទៅលោកតា កំណត់ថ្ងៃណា?

ផៃ ៖ ចាស! លោកតាខ្ញុំ លោក...

ទ្រលុត ៖ ឱ្យឆាប់ៗទៅណាផៃ ស្រុកឥឡូវទុកយូរពេកមិនបានទេ

ផៃ ៖ ចាស! លោកតា ប្រើខ្ញុំ ប្រើខ្ញុំ...

ទ្រលុក ៖ ខែកត្តិក មុននេះក៏បាន

ធា ៖ ខែកត្តិក ល្អហើយរដូវរងា

អាចារ្យ ៖ ខែកត្តិក លេខក៏ឆ្លើយថាល្អ

ផៃ ៖ ចាសទេ! លោកតាប្រើខ្ញុំឱ្យមកជម្រាបអ្នកថា

ទ្រលុក ៖ ថាម៉េច? អ្នកផៃទៅឱ្យបដាក់ត្រចៀកអ្នកទ្រលុក ខ្យល់ចាប់

ទ្រលុក ៖ កាទា កាទា គ្រាអញផង តាប៉ិកនោះគាត់មើលងាយ អញដល់ហើយហ្ន៎ កាទាយកប្រេងកូឡាឱ្យអញ

ឆួន ៖ ចុះរឿងអី?

អាចារ្យ ៖ ន... មោ-ពុទ្ធោអរហំ ពុទ្ធោអរហំ

ទ្រលុក ៖ កូនម្ដាយកុំភ័យរឿងប្ដីមិនខ្វះទេ តាប៉ិកនោះគាត់ មើលងាយឯងដល់ហើយហ្ន៎។

ស្ងួភី ៖ អ្នកម៉ែ! កូនមិនដែលភ័យ ឬមិនភ័យអរ ឬព្រួយពីរឿងប្ដី សី ដល់តិចតួចឡើយ។

អាចារ្យ ៖ ពុទ្ធោអើយ!

ទ្រលុក ៖ វាចេះតែលេខល្អ លេខល្អ

អាចារ្យ ៖ ចុះថាគេដណ្ដឹងហើយ រួចឱ្យទៅគេ ហើយ ថីក៏លេខមិនល្អ បើអ៊ីចឹងឥឡូវវាយ៉ាងម៉េចទៅ?

ទ្រលុកា ៖ យ៉ាងម៉េច! តាកញ្ចាស់នោះប្រើឈ្នួលកាផៃឱ្យមកជូនពាក្យវិញ។

អាចារ្យ ៖ បើជូនពាក្យវិញ លេខខ្ញុំអាក្រក់ទៅវិញហើយ

ផៃ ៖ សូមទោសខ្ញុំជម្រាបឱ្យស្រួលសិន លោកតាថាឱ្យខ្ញុំនិយាយជម្រាបយ៉ាងម៉េចឱ្យឃើញជូនពាក្យ តែកុំអស់សង្ឃឹមហើយនែ នែ! ឱ្យថៃទាំសូភី

ទ្រលុកា ៖ ស្អី! កញ្ចាស់វាប្រដៅអីទៀត ជូនពាក្យ វាជូនពាក្យហើយ អស់សង្ឃឹមមានសង្ឃឹមអីស្រេចតែគេ រួចថៃទាំសូភីស្អី ចង់ឌឺ ថាម៉េចហ្នឹង?។ ជម្រាបតាប៉ិកថា កុំចេះមកត្រួតត្រាអី ថៃទាំសូភី ចង់ថាម៉េចហ្នឹង?

ផៃ ៖ គាត់ថាសង្ឃឹម...

ទ្រលុកា ៖ សង្ឃឹមខ្យល់ ប្រាប់គាត់ទៅ ថ្ងៃនេះកុំតែថ្ងៃសីលទេ កុំអីលេងឱ្យអស់ដៃ រួចដើររកប្ដីឱ្យសូភីក្នុងថ្ងៃហ្នឹងទាល់តែបាន ឃើ! តាកញ្ចាស់ បាតដៃជាខ្នងដៃភ្លាម។

**អាចារ្យ ៖** អនត្តាធម៌នេះ អនុវត្តបានគ្រប់កាល គ្មានអ្វីជាទៀងទេក្នុងលោកនេះ កម្លាំងបើអាយុជីវិតដែលមនុស្សស្រឡាញ់ក៏មិនទៀងផង ចំណង់បើពាក្យសច្ចារបស់មនុស្សឱ្យទៀងម៉េច វាតែងតែប្រែប្រួលដូច្នេះឯង។ ណេ្ហីយ! អ្នកធ្វើ ចិត្តឱ្យស្ងប់ទៅ មករៀបខ្លួនទៅវត្តរក្សាឱបោសថសីល។ ចៅស្រី កុំមានញោចអារម្មណ៍អ្វីចំពោះរឿងនេះវាសនារបស់មនុស្សរមែងមានដំណើរទៅតាមកម្មផល ។

**ស្ងួភី ៖** លោកតាអាចារ្យ! ខ្ញុំពុំចេះធម៌អាថ៌ និយាយបាលី បាគូសូត្រចេញជាក្បួនខ្នាតអ្វីទេ តែក្នុងរឿងទាំងនេះខ្ញុំបានជម្រាបអ្នកម៉ែ អ៊ំមីងទា និងលោកតាអាចារ្យស្រាប់ហើយថា អារម្មណ៍ខ្ញុំពុំមានញោចទេបានដំណឹងថានឹងត្រូវមានប្ដីនោះ ហើយលុះត្រឡប់ទៅជាពុំទាន់បានប្ដីទៅវិញ ក៏អារម្មណ៍ពុំមានញោចដល់តិចតួចឡើយ។ សព្វថ្ងៃនេះ ខ្ញុំខំរក្សាសាងតែអំពើល្អ ដើម្បីលាងកម្មពៀរដែលមានពីជាតិមុន ហើយប្រសិនណាជាជាតិមុខនឹងបានកើតទៅជាមនុស្សទៀត សូមឱ្យមានជីវិតពើបប្រទះតែនឹងសេចក្ដីសុខ អំពើល្អ ។

មីងផៃ! ជម្រាបទៅលោកតានោះផង ជម្រាបទៅអ្នកកំលោះនោះផងថាកុំចាំបាច់មកព្រួយជួយឃ្លាំមើលខ្លួនខ្ញុំធ្វើអ្វី អ្នកម៉ែខ្ញុំតែងប្រដៅខ្ញុំមកឱ្យខ្ញុំយល់ថា នៅទីបំផុតចិត្តខ្ញុំជាម្ចាស់ជីវិតរបស់ខ្ញុំ ហើយចិត្តខ្ញុំនេះប្រាថ្នាសាងតែអំពើល្អទៅតាមគន្លងធម៌ប្រពៃណីខ្មែរនឹងព្រះពុទ្ធសាសនា។

**ផៃ ៖** ក្នុងរឿងនេះជឿខ្ញុំចុះ ខ្ញុំជាអ្នកស្តាយជាងគេ ព្រោះគ្រាន់តែឃើញនាងនឹងឮសម្ដីនាងនិយាយនេះ ខ្ញុំកោតស្ញើចសរសើរដល់នាងឥតឧបមា ជម្រាបលាសិនហើយចាស! លាហើយសូភីសូមឱ្យនាងស្គាល់តែសេចក្តីសុខនិងសប្បាយ។

**ទ្រលុកា ៖** យើ ! យាយប៉ិកនេះនាំទុក្ខមកឱ្យអញ រួចវាមកដាក់ផ្លែផ្កាថាឱ្យស្គាល់តែសេចក្ដីសុខសប្បាយ ផ្ដាំទៅតាប៉ិកកញ្ចាស់ផង តែប៉ុណ្ណេះលែងមើលមុខគ្នាទៅ

ណ្ហើយកូនមាសម្ដាយ! ប្ដីមិនខ្វះទេ ព្រឹកនេះមើលថៃទាំផ្ទះ សម្បែងណា៎ ម៉ែទៅរក្សាឱបោសថសីល ម៉ែនៅឯវត្ត ឯណោះទាល់តែល្ងាចជិតយប់បានម៉ែមកផ្ទះវិញ... កាទា មើលសូភីផងណា ឆ្មាមិននៅកុំកណ្ដុរឡើងរាជ្យ...។

**សូភី ៖** ម៉ែ កូនមើលចប់ច្បាប់ស្រីហើយ កូនចង់មើលរឿងទុំទាវបានទេម៉ែ?

**អាចារ្យ ៖** ទុំទាវក៏បាន ព្រះវេស្សន្តរក៏បាន រាមកេរ្តិ៍ក៏បាន ថៅអើយ សុទ្ធតែកំណប់ពេជ្រនៃអក្សរសាស្ត្រជាតិណា។

**ទ្រលុកា ៖** មើលចុះ! ទុំទាវ តែកុំចចេសដូចនាងទាវណា

ទាំងអស់គ្នា ទាំងអស់គ្នា ចេញទៅ។

ណាជីណា ៖ ទុំទាវ ក្រែងនាងមើលចប់ពីរបីដងហើយ

ស្ងូភី ៖ ចាស! ចប់ពីរបីដងមែន តែខ្ញុំពុំបានសុំច្បាប់ម៉ែណា៎ មិនគ្រាន់តែមើលចប់ទេ ខ្ញុំទន្ទេញចាំមាត់ផង

ណា ៖ មីងនៅនឹងនាងយូរហើយពុំស្គាល់ចិត្តនាងសោះ នាងដូចជាត្រង់ តែវៀចដែរ ដូចជាខ្លាចម៉ែណាស់ ដូចជាមិនខ្លាចទេ មែនមីងមើលចិត្តនាងមិនធ្លុះទេ។

ស្ងូភី ៖ មីងអើយ! អ្នកណាឡើយមើលចិត្តមនុស្សធ្លុះ ខ្លួនខ្ញុំឯងមិនទាំងស្គាល់ថាចិត្តខ្ញុំយ៉ាងណាផង ចិត្តខ្ញុំ

ស្រេចពីគោចរទៅតាមតែគេចង់ ពេលដែលម៉ែឃាំងខ្ញុំ ក្នុងបន្ទប់គ្រាន់តែបើកបង្អួចបន្តិចរស្មីព្រះអាទិត្យចូលមកអន្ទងចិត្តខ្ញុំភ្លាម ទទួលបានជំនោរខ្យល់បក់មក ក៏អណ្ដែតចិត្តឥតម្ចាស់ នេះឱ្យដើរត្រេចទៅត្រេចទៅ ឃើញអស់ហើយទេសភាពខៀវស្រងាត់ដោយព្រឹក្សា ត្រឈឹងត្រឈៃ ឮអស់ហើយហើយសំឡេងប្រគំតន្ត្រីដោយបក្សីបក្សា ខ្លួនខ្ញុំនៅក្នុងទ្រុងមាសរបស់ម៉ែមែន តែចិត្តខ្ញុំបានទៅក្រេបក្លិនក្រអូបនៃគន្ធពិដោរបុប្ផាដេរដាសលើពសុធា បានទៅកម្សាន្តសប្បាយ ថ្វីត្បិតតែឥតសេចក្ដីអនុញ្ញាតពីខ្លួនខ្ញុំ ថ្វីត្បិតតែមានសេចក្ដីអនុញ្ញាតពីអ្នកម៉ែ ឃើញទេមីងទា មីងស្គាល់ចិត្តខ្ញុំឯណាបាន បើខ្លួនខ្ញុំពុំស្គាល់ចិត្តខ្ញុំផង។

**មីជ័ជា** ៖ ចុះនាងក៏ឯងចង់បានប្តីទេ?

**សូភី** ៖ នាងទាវស្លាប់ព្រោះស្រឡាញ់ប្តី ចុះខ្ញុំ ខ្ញុំជាចិត្តទាវ ខ្ញុំយល់ចិត្តទាវណាស់នាងថា ៖

ទុំអើយម្ល៉េះហើយទាវមិនរស់ ស៊ូស្លាប់តាមប្រុសឱ្យសូន្យ
ម្តាយឥតករុណាមេត្តាកូន មិនដោយដំបូន្មានប្រដៅ។

**ទាវ** ៖ ទាវគេស្រឡាញ់ទុំ ចុះមុំឯងស្រឡាញ់នរណា?

## សង្ហាលបចូល

**សូភី** ៖ ខ្ញុំស្រឡាញ់ប្រុសណា ដែលប្តូរស្លាប់នឹងខ្ញុំដូចទុំប្តូរស្លាប់នឹងទាវ ព្រោះក្នុងជីវិតនេះ ទោះបីអ្វីៗមិនទៀង ក៏សេចក្តីស្នេហាត្រូវតែទៀង ស្នេហាតែមួយ ស្នេហា ប្តូរផ្តាច់ ស្នេហាអស់មួយជីវិត

**សង្ហា** ៖ និយាយម្នាក់ឯង បើសូភីស៊ូស្លាប់នឹងសង្ហា

## នាយសង្ហាធ្វើឫកដារឫសដៃដើរចូលមកក្នុងផ្ទះ

សង្ហាក៏ស៊ូស្លាប់នឹងសូភីដែរ ពុទ្ធោអើយសូភីអីគេ នេះល្អមែនល្អមែន។ ឱចិត្តកុំអាលរំជួល កុំអាលប្តូរ

**សង្ហា** ៖ លោកអ្នកណាអើយ គិតតែពីស្នេហាតែមួយ ស្នេហាប្តូរផ្តាច់ ស្នេហាអស់មួយជីវិត នៅពេលដែលខ្លួនខ្ញុំទទួលរងគ្រោះបាក់ដៃស្ទើរស្លាប់។ ធ្វើពុតជាដួល។

ធា ៖ យីអ្នកណាអីចេះហ៊ានចូលក្នុងផ្ទះនេះ អ្នកស្រីជ្រាប ងាប់យើងហើយចេញឱ្យឆាប់ទៅ នៅមិនបានទេ យីប្រុសណាអ៊ីចេះ!

សង្ហា ៖ ខ្ញុំមានគ្រោះថ្នាក់បាក់ដៃ ពុំដឹងទៅណាថាចូលមកស្លាប់នៅទីនេះ ស្រាប់តែសូរសំឡេងពីរោះរបស់នារីវិស័យដូចជាថ្នាំទិព្វបានមកចាក់ដល់កាយខ្ញុំ ឱ្យមានកម្លាំងព្រឹស ហើយខំប្រឹងតទល់នឹងមច្ចុរាជ ព្រោះថាក្នុងជីវិតមិនមែនមានតែសំឡេងអ័ព្ទអួទេ សំឡេងប្រទូសរ៉ាយច្រណែន និន្ទាឈ្លោះគ្នារវាងមនុស្សនឹងមនុស្សទេ នៅមានសំឡេងនារីដ៏ពីរោះរណ្តំឡើងយ៉ាងក្រអួនចេញពីក្រអៅបេះដូង ចែងថាស្នេហាតែមួយ ស្នេហាប្តូរផ្តាច់ ស្នេហាអស់មួយជីវិត។

ធា ៖ ងាប់ហើយ! ស្នេហា ស្នេហាទីនេះចេញឱ្យឆាប់ទៅ អ្នកមកពីវត្តវាយងាប់អស់ហើយ។

សង្ហា ៖ អ៊ីយូយ! ស្រេកទឹកណាស់ មុននឹងត្រូវបណ្តេញចេញទៅ មេត្តាសុំទឹកទទួលទានបន្តិចមក ឱនារីដ៏សប្បុរសអើយ មេត្តាយកតែបុណ្យទៅចុះ។

### នាងសូភីទៅយកទឹកមានផ្កាកូឡាបមកឱ្យសង្ហា

សូភី ៖ អញ្ជើញពិសាទឹក

ធា ៖ ហើយចេញឱ្យឆាប់ទៅ

សុភី ៖ មីងថ្ងៃនេះថ្ងៃសីលផង ទោះបីសត្វមានរបួសក៏ព្រះពុទ្ធជាម្ចាស់ទ្រង់បង្គាប់ឱ្យសន្ដោសដល់ដែរ កម្លាំងបើមនុស្ស។

ធា ៖ អ្នកម៉ែ! នាងមកវាយខ្មែចខ្ចីហើយ

សុភី ៖ អ្នកម៉ែខ្ញុំជាអ្នកកាន់ព្រះពុទ្ធសាសនា តែងប្រដៅខ្ញុំថាឱ្យមានចិត្តទោរទន់ សន្ដោសអ្នកផង

ធា ៖ អើ អើ! ប៉ុន្ដែ នែ នែ! គេនេះជាប្រុសកំលោះ រួចឯងនេះវាក្រមុំ

សុភី ៖ មានរឿងអីជាចម្លែក កុំថាប្រុសកំលោះ ទោះបីជាស្មូមយាចកក៏យើងតោងតែយកអាសា។

សឌ្ឍា ៖ និយាយដូចនាងបានស្រួលស្ដាប់ មីងឯណេះមិនកើតទេ ប្រាំបីធានដាក់មនុស្សរបួសតែម្ដង។

សុភី ៖ សូមលោកកុំប្រកាន់គាត់ មុខងាររបស់គាត់ត្រូវតែរក្សាការពារខ្ញុំ

សឌ្ឍា ៖ នាងមានវាចា មានប្រាជ្ញា មានយោបល់ដល់ទៅម្លឹងគួរតែនាងវិញទេដែលត្រូវការពារ មីងឯណេះមិនមែនមីងឯណោះត្រូវការពារនាងទេ។

ធា ៖ កូនគេវាក្រមុំព្រហ្មចារី

សង្ហា៖ រួចកើតអីបានជាចាំការពារ ឃើញពន្លឺថ្ងៃមិនបានឃើញផ្កាយលើមេឃមិនបាន មើលសៀវភៅមិនបាន ឃើញប្រុសមិនបាន?

ធា ៖ អើ! ប្រុសឥឡូវគេមិនទុកចិត្តទេ

សង្ហា ៖ បើស្រីមិនទុកចិត្តលើប្រុស ប្រុសមិនទុកចិត្តលើស្រី លោកយើងនេះយ៉ាងណាទៅ?

ធា ៖ ស្រីថីមិនទុកចិត្តលើប្រុស តែប្រុសហ្នឹងបោកស្រី យើងហ្នឹងមិនទុកចិត្តលើលោកឯង។

សង្ហា ៖ ខ្ញុំវាថី! ប្លែកគេត្រង់ណា ភ្នែកតែម្ខាង មាត់បណ្ដោយប្រមុះ...

សូភី ៖ មីងទា កុំនិយាយច្រើនពេកណា រីឯលោកនេះដូចជាបាត់ឈឺដៃទៅហើយ។

សង្ហា ៖ អូមែន! អីយូយ! អីយូយ! ធ្វើម៉េចបានគ្រូណាជួយមើលផង។

សូភី ៖ អូមែន! មីងទាទៅអញ្ជើញគ្រូអាំមក គាត់ចេះចតឈាម។

សង្ហា ៖ មីងទាទៅ បាននរណាមើលអ្នកនាង?

ធា ៖ អត់ទៅទេ!

ស្ងូភី ៖ ម៉េចក៏ចាំមានគេឃ្វាលខ្ញុំ ខ្ញុំកូនចៀមឬ?

ធា ៖ អត់ទៅទេគ្រូនេះគេយកកំណល់ផង

សង្ហ្វា ៖ អូ! សូមអញ្ជើញនេះក្រដាសប្រាំរយ

មីងទាស្ទុះទៅយក តែនាងស្ងូភីរហ័សឃាត់

ស្ងូភី ៖ កុំមីងទា! ទៅអញ្ជើញលោកគ្រូមកសិនមកថា ខ្ញុំសូមអញ្ជើញទៀនធូបឯណោះ ទៅកំណល់រណ្តាប់រណ្តោយអីចាំយកពីខ្ញុំ។

ធា ៖ អ្នកនាងចូលក្នុងបន្ទប់ទៅ ខ្ញុំចាក់សោ

ស្ងូភី៖ មិនគិតទៅទេ គិតតែមកដាក់គុកឯងទៅវិញ ទៅចេញទៅ

សង្ហ្វា ៖ អ្នកនាងនៅតែពីរនាក់ខ្ញុំដូច្នេះមិនខ្លាចខ្ញុំទេឬ?

ស្ងូភី ៖ មានរឿងអី ខ្ញុំត្រូវខ្លាចលោក លោកខ្លាច

សង្ហ្វា ៖ ស្រុកឥឡូវមនុស្សប្រុសអាក្រក់ជាងខ្លា ជាងសិង្ហ ជាងក្រពើទៅទៀត សត្វ សត្វ វាធ្វើបាបមនុស្ស ពីព្រោះវាឃ្លាន រីឯប្រុសៗធ្វើបាបស្រី ពីព្រោះមានគំនិតអាក្រក់ជាងសត្វទៅទៀត។

សុភី ៖ លោកដែលចេះនិយាយដូច្នេះ ខ្ញុំហ៊ានសង្ស័យថា លោកមិនមែនអាក្រក់ជាងខ្លា ជាងសិង្ហ ជាងក្រពើទៀតទេ ម៉េចទៅដែលធ្វើម៉េចខ្ញុំមិនមែនគ្រូពេទ្យ ខ្ញុំមិនមែនគ្រូផ្លុំ ខ្ញុំពុំដឹងជួយសម្រាលជំងឺរបស់លោកជាងនេះទៅទៀតបានទេ អូមែន! ខ្ញុំមានប្រេងភូមាក្រែងលោកវិលមុខ ខ្ញុំទៅយកមកជូន នាងចូលទៅក្នុង

សង្ហា ៖ និយាយតែម្នាក់ឯង ៖ អាសង្ហា អាឯងនេះអាក្រក់ជាងខ្លា ជាងសិង្ហ ជាងក្រពើទៅទៀត គួរអើមកធ្វើពុតជាឈឺបញ្ឆោតស្រីស្លូតត្រង់។

សុភី ៖ ចេញមក នេះប្រេងភូមា លាបមុខបន្តិចទៅក្រែងវិលមុខ ទំរាំហ្មមកដល់ ស្រុកស្រែលោកអើយធ្វើម៉េចដូចពេទ្យភ្នំពេញ។

សង្ហា ៖ តែស្រីស្រុកស្រែល្អជាងស្រីនៅភ្នំពេញ

សុភី ៖ លោកដូចជាមិនសូវគិតពីជំងឺដែរសោះ ខ្ញុំសំគាល់មើលទៅច្រើនតែនិយាយក្រៅរឿង។

សង្ហា ៖ តើអ្នកនាងអនុញ្ញាតឱ្យខ្ញុំនិយាយក្រៅរឿងតទៅទៀតបានទេ?

សុភី ៖ កាលនិយាយមុនៗ លោកមានបានសុំអនុញ្ញាតពីខ្ញុំឯណា

សង្ហា៖ គឺថា! ខ្ញុំនិយាយទៅទៀតបាន អ្នកនាង មានគូដណ្តឹងហើយឬនៅ

ស្វូភី ៖ សើច

សង្ហា ៖ ម៉េចសើច! សំណួរខ្ញុំនេះឆ្គងណាស់ឬ?

ស្វូភី ៖ ខ្ញុំសើចព្រោះរឿងខ្ញុំក្បែរៗ តែនឹងរឿងល្ខោនព្រឹកមិញនេះ ម៉ែខ្ញុំប្រាប់ថាមានលោកតាម្នាក់មកស្តីដណ្តឹងខ្ញុំឱ្យទៅចៅគាត់ គាត់ក៏ព្រមឱ្យខ្ញុំទៅគេស្រាប់តែថាគេជូនពាក្យវិញ

សង្ហា ៖ យី! អ្នកណាមួយហ៊ានមើលងាយអ្នកនាងដល់ម្លឹង

ស្វូភី ៖ គេមានមើលងាយឯណា ពីដើមគេចង់បានខ្ញុំ ដល់គេមិនចង់បានវិញទៅ គេត្រូវតែជូនពាក្យវិញអ៊ីចឹងហើយ ជារឿងធម្មតាមានរឿងអ្វីថាមើលងាយនោះ

សង្ហា ៖ អ្នកនាងគ្មានខឹង គ្មានអរ គ្មានព្រួយ គ្មានអៀនអីទេ

ស្វូភី ៖ ខ្ញុំអត់ទេ អ្នកម៉ែខ្ញុំទេ គាត់ខឹងខ្លះដែរ គាត់ថាតានោះនិយាយបាតដៃជាខ្នងដៃ។

សង្ហា ៖ ខ្ញុំថប់តែមកពីចៅគាត់ទេ យុវជនយើងឥឡូវគេរើសគូស្រករណាស់ណា គេចង់ទាក់ទងមុនអាចង់ឃើញ គេចង់ស្ទង់ចិត្ត គេចង់ធ្វើហ្វីយ៉ង់សេរ ខ្ញុំមើលទៅច្បាស់ជាមកពីចៅគាត់ហើយ អានោះឮថាខូចណាស់ ខិលណាស់អ្នកនាងស្រឡាញ់វាដែរ។

សុភី ៖ លោកស្គាល់គេទេ បានដឹងថាគេខិលគេខូច

សង្ហា ៖ ទេ ទេ! ខ្ញុំឥតស្គាល់គេទេ

សុភី ៖ បើមិនស្គាល់ម៉េចហ៊ានថា

សង្ហា ៖ ខ្ញុំស្មាន ខ្ញុំប៉ាន់

សុភី ៖ លោកពូកែខាងស្មាន ខាងប៉ាន់ណាស់ហើយមើលទៅ តាមខ្ញុំយល់សេចក្ដីស្មានច្រើនតែមិនពិតទេ រឿងស្អីៗក្នុងលោកនេះ គួរតែយើងបញ្ជាក់ឱ្យច្បាស់សិន សូមហ៊ានថាតែស្មាន វាចេះតែប្រឡំ ហើយវានាំឱ្យខុស ហើយចេះតែខូចការជរាបរៀងទៅៗ ម៉េចទៅដែលោក ?

សង្ហា ៖ អូមែន! អ៊ីយូយ!

សុភី ៖ ចម្លែកណាស់ដែនេះ ទាល់តែខ្ញុំសួរបានចេះឆ្លើយ ណ្ហើយ ខ្ញុំឈប់សួរហើយ

សង្ហា ៖ អ្នកនាង! បើខ្ញុំធ្វើខុសចំពោះអ្នកនាង តើអ្នកនាងនឹងអត់ទោសឱ្យខ្ញុំឬទេ ?

សុភី ៖ លោកមានខុសអីចំពោះខ្ញុំ

សង្ហា ៖ ទេខ្ញុំបានជាខុសទៅហើយ

សុភី ៖ ពុទ្ធោអើយ! ព្រះម្ចាស់អើយ ខុសអី?

សង្ហា ៖ ចង់យំ! ខ្ញុំខុសណាស់ទៅហើយ ខ្ញុំជាមនុស្សមានជីវិតដែលប្រាប់ខ្ញុំឱ្យចេះតែយល់ច្រឡំ ខ្ញុំយល់ច្រឡំថាស្រីខ្មែរដែលជាសំពត់ក្នុងផ្នត់គ្មានទេ បើមានគឺនាង នោះល្ងង់ ជាមនុស្សមិនដឹងខ្យល់ ជាមនុស្សដែលគេខ្ជប់ ជាមនុស្សយកជាគ្នាមិនបាន តែបើត្រឡប់ជាស៊ីវិល័យវិញ ស្រីខ្មែរនោះយល់អរិយធម៌ខុស មកតែពីខ្យល់ទំនើបមកប៉ះខ្លួនទៅជាហ៊ឺហាខុសបែបបទ មានចិត្តមមើមមាយ សាវ៉ា រកនឹងយកជាគ្នាធ្វើជាគូជីវិតមិនបាន។ រីឯអ្នកនាងវិញ

សុភី ៖ យីលោកគិតតែមកលួងខ្ញុំតែម្តងឬ? ជម្រាបលោកឈើដៃឱ្យច្បាស់ជាឈើដៃ និយាយលេងពីនេះពីនោះ ឱ្យច្បាស់ជានិយាយលេង លោកថាបានធ្វើខុសចំពោះខ្ញុំតាមខ្ញុំយល់ពុំទាន់បានធ្វើខុសទេ តែកំពុងអង្អឹលទៅរកខុសហើយ...។

សង្ហា ៖ ទេ! ខ្ញុំបានធ្វើខុសចំពោះអស់លោក អ្នកនាងរួចទៅហើយ ខ្ញុំគ្មានរបួសដែងណាទេ ខ្ញុំបានភរអ្នកនាងទេ រួចចៅតាដែលបានមកដណ្តឹងនាង ហើយជូនពាក្យទៅវិញនោះគឺខ្ញុំនេះឯង។

សុភី ៖ ... ពុទ្ធោ!

សង្ហា៖ ដើរប្រទេចផ្កាសាខ្ញុំមក ចង្អុលមុខខ្ញុំមក ស្ដីបន្ទោសខ្ញុំមក ខ្ញុំបានខុសហើយ ថែមទាំងបាននាំលោកតាខ្ញុំ មកឱ្យខុសជាមួយទៀតផង ហេតុដូច្នេះហើយបានជាខ្ញុំថាខ្ញុំនេះអាក្រក់ជាងខ្លា ជាងសិង្ហជាងក្រពើ តែខ្លាខ្ញុំ សិង្ហខ្ញុំ ត្រូវនូវខ្សែចិត្ត និងខ្សែនេត្រា ទឹកក្រុតរបស់អ្នកនាង ក៏ត្រឡប់ទៅជាស្លូត ហើយសូមបើកក្រអៅបេះដូងជម្រាបនាងថា ខ្ញុំបានពើបប្រទះតែកញ្ញាមួយដែលនៅទៅជាស់អារម្មណ៍ស្នេហាខ្ញុំឱ្យតែរំជួយញាប់ញ័រ មានឥទ្ធិពលមកផ្លាស់គំនិតខ្ញុំជាថ្មីឱ្យយល់ថាទោះបីនៅសតវត្សទី២០ សតវត្សបរមាណូ សតវត្សស្ពុតនិក គង់សេចក្ដីស្នេហានៅតែមានន័យ គង់តែនៅមាននារីខ្មែរ អាចទៅជាបណ្ដូលចិត្ត គង់នៅមានគូសង្សារជឿលើស្នេហាអស់មួយជីវិត គង់នៅមានរ៉ូមេអូ ហ្ស៊ុលលីយេត គង់នៅមានប៉ូលវីរហ្សឺនីគង់នៅមានទុំ-ទាវ។

សង្ហាស្ទុះទៅកាន់ដៃនាងសូភីដែលព្រមទទួល តន្ត្រីស្នេហាបន្លឺឡើង រាំងននធ្លាក់

## ចប់ឈុតទី២

## ឈុតទី ៣

ឆាកល្ខោនត្រូវចែកជាពីរ ម្ខាងឱ្យឃើញបន្ទប់ផ្ទះលោកតាភោគផល ដែលគេឃើញមីងផៃអង្គុយយំ សង្ខាសំពះអង្វរលោកតាភោគផល។ ឆាកម្ខាងទៀតឃើញបន្ទប់ផ្ទះអ្នកទ្រលុក មីងទាអង្គុយយំ នាងសូភីអង្គុយអង្វរអ្នកទ្រលុក ភ្លើងល្ខោនភ្លឺខាងណា ខាងនោះចេញសំដែង។

ប៉ូល ៖ រ៉ូមេអូ ហ្ស៊ុលលីយេត ប៉ូល អេ វីរហ្សីនី ទុំទាវ ឥឡូវនេះ សង្ខា សូភី នៅផ្ទះរៀងខ្លួន។ តួរកំសត់ទាំងនេះនៅពេលជាមួយគ្នាមានសកម្មស្រដៀងគ្នា។

តា ៖ ទេ ទេ! ដាជាច់ខាត អញមិនឱ្យអាឯងយកនាង សូភីដែលអាឯងទៅចង់តែ៥នាទីបាននោះទេ

សង្ខា ៖ លោកតាកុំមានប្រសាសន៍អ៊ីចឹង សូភីជាស្រីគ្រប់លក្ខណ៍ តែសេចក្ដីស្នេហាមានកម្លាំងប្លែកណាស់ ជួនកាលអស់ពេលយ៉ាងយូរទើបស្នេហាពន្លកទៅបាន ជួនកាលត្រូវយកវិចារណញ្ញាណទៅជួយ ទើបបំផុសនឹងទ្រទ្រុងស្នេហាបាន តែប្លែកណាស់ទៅទៀតជួនកាល មួយវិនាទីសោះសេចក្ដីស្នេហាបដិសន្ធិឡើងធំធាត់ភ្លាមមានកម្លាំងភ្លាម ស្នេហាដែលកើតបែបនេះមិនអាចឱ្យយើងទៅចោទដល់គូស្នេហាថាមានចិត្តឆេវឆាវនោះទេ។

តា ៖ ចុះការពិសោធដែលឯងសន្យាជាមួយនឹងអញសំដីកូនប្រុសរបស់អាឯងយ៉ាងណាទៅវិញ នែ! អញប្រាប់ហើយប្រាប់ទៀតណា៎ អញទៅដណ្ដឹងកូនគេអ្នកកំពង់ឆ្នាំងមួយទៀតហើយ ផ្ដាច់ការទាក់ទងឡើងចុះ ផ្ដាច់សំបុត្រស្នាមស្នេហា ផ្ដាច់ការជួបក្នុងសួនក្នុងព្រៃជាមួយនឹងមីសូភីតាំងពីថ្ងៃនេះទៅ

សង្ហា ៖ គឺថា ចង់ខ្ទប់ច្រមុះខ្ញុំឱ្យលែងដកដង្ហើមទៅកើត ចង់ខ្ទាស់បេះដូងខ្ញុំឱ្យលែងដើរ បញ្ឈប់ឈាមខ្ញុំឱ្យឈប់រត់ក្នុងសរសៃ បញ្ជូនខ្ញុំឱ្យចាកស្ថានមនុស្សនេះទៅកាន់មរណភាពឬ?

លោកតា ថៅសំពះ ថៅឱបបាទជើង ថៅអង្វរ ថៅស្រឡាញ់តែសូភីម្នាក់ទេ។

តា ៖ ទេ ទេ! អញថាទេ ទេ!

សង្ហា ៖ ខ្ញុំធ្លាប់ស្គាល់ជំងឺគ្រប់បែបយ៉ាង តែគ្មានអ្វីមកធ្វើឱ្យខ្ញុំឈឺចាប់ដូចពាក្យ ទេ ទេ! របស់លោកតាទេ សូភីអូនអើយ អូននៅឯណា ចំពោះបង បងកំពុងអង្វរលោកតាបងឱ្យព្រមទទួលស្គាល់ស្នេហាដ៏បរិសុទ្ធរបស់យើង។ សូភី! អូនអើយពេលនេះអូននៅឆ្ងាយពីបងពិត តែបងហាក់ដូចជាឃើញអូននៅនឹងភ្នែក នៅជិតបងបង្ហើយឮសូរសំឡេងអូនល្ងើយៗ សំឡេងការពារសេចក្ដីស្នេហាបរិសុទ្ធរបស់យើង។

(ភ្លើងរលត់ខាងបន្ទប់លោកតាភោគផល នៅភ្លឺខាងបន្ទប់អ្នកទ្រលុក ឃើញមីងទាអង្គុយយំ នាងសូភីអង្វរម្ដាយ)

ទ្រលុក ៖ ទេ ទេ! ដាច់ខាត តែមិនឱ្យកូនធ្លាក់ទៅក្នុងកណ្ដាប់ដៃក្មេងពាលអាសង្ហាទេ

សូភី ៖ អ្នកម៉ែជាទីគោរព! ជាព្រះម្ចាស់របស់កូន! បើអ្នកម៉ែឃើញកូនមកហ៊ានរឹងរូស ហ៊ានអង្វរករអ្នកម៉ែដូច្នេះមកពីទំហំចិត្តស្នេហារបស់កូនធំណាស់ កម្លាំងស្នេហាបរិសុទ្ធនេះហើយដែលនិយាយខ្សាវៗ រាល់វិនាទីប្រាប់កូនថា ត្រូវតែអង្វរ ត្រូវតែធ្វើយ៉ាងណាឱ្យខាងតែបានសម្រេចស្នេហាតែមួយដូចបំណង។

ទ្រលុក ៖ ភ្លេចអស់ហើយឬ? ពាក្យដំបូន្មានដែលថាកូនស្រីត្រូវតែស្ដាប់បង្គាប់ឪពុកម្ដាយ ហើយម្យ៉ាងទៀតអញសូមរំលឹកឯងថាលោកបាឡាត់គេមកសុំភ្ជាប់ពាក្យហើយម៉ែលើកកូនឯងឱ្យទៅគេហើយពីថ្ងៃនេះទៅឈប់ទទួលនិយាយជាមួយ ឈប់ទទួលសំបុត្រឈប់មានការទាក់ទងជាមួយនឹងអាសង្ហាទៀតទៅ ខុសឆ្គងតិចតួចពីនោះមកម៉ែលើកទោសឱ្យ ឱ្យតែពីថ្ងៃនេះទៅកូនធ្វើតាមម្ដាយទៅវិញ ឈប់ជួបនឹងអាសង្ហា គឺផ្ដាច់ជាមួយអាសង្ហា។

សូភី ៖ បានសេចក្ដីថា គឺសង្ខារកូនអាចរលត់តែប៉ុណ្ណោះ ឱ! អ្នកម៉ែអើយ កូនសំពះ កូនឱបជើងម្ដាយ ឱ្យតែអ្នកម៉ែមេត្តាចុះព្រមតាមកូន បន្ធូយមនោសញ្ចេតនាកូនដែលហូរចាក់តម្រង់ទៅរកតែគូសង្សារតែមួយនោះ គឺបងសង្ខានេះឯង។

ទ្រលុក ៖ ចេះតែអាសង្ខា អាសង្ខា អញស្អប់តាប៉ិកនោះសឹងងាប់ លោកបាឡាត់ឯណោះមិនគិតទេគិតតែអាសង្ខា...

សូភី ៖ ឱ! បងសង្ខាអូនអើយ ទោះបីអូនបិទភ្នែក បិទត្រចៀកខ្ទប់អារម្មណ៍យ៉ាងណាក៏អូននៅតែឃើញបង ក៏អូននៅតែឮសំឡេងពីរោះរបស់បង ក៏ដវនចិត្តអូននៅតែទៅជំពាក់ជាមួយដវនចិត្តរបស់បង។ ម្ល៉េះសមបងកំពុងមានទុក្ខព្រោះរឿងនេះយ៉ាងណាទៅ

ភ្លើងរលត់ ភ្លឺខាងម្ខាងវិញ។ តានិយាយ

តា ៖ អញថប់តែអ្នកទ្រលុកគាត់មានគ្រូស្នេហ៍ទេមើលទៅ ព្រោះអាឯងនេះជាប្រុសធ្លាប់ដើរលេងស៊ីផឹកស្គាល់ស្រីញី ចុះជំនុំចំណោមនឹងគេដែរ ឥឡូវគ្រាន់តែឃើញសូភីមួយនាទីពីរ ក៏វាផ្លាស់សជាខ្មៅ ខ្មៅជាសទៅហើយ។ អាឯងទៅជាមនុស្សកំសាកជ្រោយចាញ់សេចក្ដីស្នេហាចេះថ្ងូរមើលតែព្រាបស្អិតមើលតែឈ្លើង...

សង្ហា ៖ មែនហើយ ពីដើមខ្ញុំយល់ច្រឡំថាខ្ញុំជាប្រុសមួយនាក់ស្គាល់ជីវិតស្រី ស្គាល់ក្រឡុកក្រលៀត ស្គាល់បេះដូងស្រីគ្រប់ជ្រុង ហើយចេះកាន់យកមកបង្វិលមើលបានតាមចិត្ត ស្គាល់ផ្នត់គំនិតមនុស្សគ្មានសល់ តែតាមការពិត ខ្ញុំស្គាល់មនុស្សតែសើរៗ តែសំបកក្រៅ ស្គាល់ស្រីតែមួយប្រភេទ ប្រភេទពួកល្មើមនឹងជីវិត ពួកមិនជឿលើចិត្តបរិសុទ្ធរបស់ស្នេហា។ តែវាសនាប្រទានខ្ញុំឱ្យប្រទះនឹងអូនសូភី ដែលរូបក្រៅឥតមានរចនាច្នៃអ្វីឱ្យលើសពីធម្មជាតិប៉ុន្មាន ខ្ញុំក៏យល់ថាជីវិតមានន័យ ចិត្តស្នេហាជាមនោសញ្ចេតនាច្បងលើមនោសញ្ចេតនានានា។

តា៖ យី! អានេះប្រំដែលៗ អញនិយាយតែខ្លីអាណានាំធ្វើពិសោធមិនក្បាលអាឯង អញដោយតាមអាឯង អញឈប់ដណ្ដឹងនាងសូភីហើយ អញទៅដណ្ដឹងកូនគេមួយទៀតឱ្យ។

សង្ហា ៖ មែនហើយខ្ញុំនាំធ្វើការពិសោធ ដល់ពិសោធទៅក៏ឃើញថា ខ្ញុំស្រឡាញ់នាងសូភីមែន។

តា ៖ អញមិនស្រឡាញ់! អញមិនឱ្យឯងយកសូភី

សង្ហា ៖ ខ្ញុំស្រឡាញ់! ខ្ញុំយកសូភី

តា ៖ អាឯងរឹងក្បាលឬ?

សង្ហា ៖ ព្រោះស្នេហា! ព្រោះសូភី!

## ពន្ធត់ភ្លាមទៅភ្លឺងខាងផ្ទះអ្នកទ្រលុក

ស្វូភី ៖ អ្នកម៉ែ! អ្នកម៉ែបានអនុញ្ញាតឱ្យកូនមើលសៀវភៅទុំទាវ កូនមិនគ្រាន់តែបានមើលទេ កូនទន្ទេញចាំទាំងមាត់ មិនគ្រាន់តែទន្ទេញចាំមាត់ថែមទាំងមានព្រលឹងដូចនាងទាវមកសណ្ឋិតលើខ្លួនកូនផង។ អ្នកម៉ែជួយគិតមើលផងមើល រឿងរបស់កូននេះតិចលោមានការដោះស្រាយបែបរឿងទុំទាវទៅ។

ទ្រលុក ៖ ឃើញទេ ម៉ែមិនចង់ឱ្យមើលសៀវភៅហ្នឹងត្រូវមែនណា កូនមាសម្ដាយកុំបណ្ដោយអាត្មាខ្លួនឱ្យស្អីៗខាងក្រៅដឹកនាំបាននោះ ត្រូវប្រុងឱ្យនឹងតាំងចិត្តជំនះ...

ស្វូភី ៖ មានតែអ្នកម៉ែទេ ដែលជួយកូនបានក្នុងរឿងនេះ

ទ្រលុក ៖ ម៉ែជួយហើយហ្នឹងណា

ស្វូភី ៖ បើម៉ែជួយ ម៉ែព្រមឱ្យស្រឡាញ់បងសង្ហាទៅ

ទ្រលុក ៖ មិនបានទេកូន ម៉ែស្អប់ជីតាគេណាស់

ស្វូភី ៖ កម្មកូន កូនស្រឡាញ់បងសង្ហា

ទ្រលុក ៖ កុំធ្វើក្បាលរឹងណា

ស្វូភី ៖ ក្បាលរឹងព្រោះស្នេហា ព្រោះសង្ហា។

### ភ្លើងភ្លឺខាងសង្ហាភ្លាម។ ភ្លឺទាំងសងខាង

តា ៖ ដាច់ខាតអញមិនឱ្យអាឯងការជាមួយសូភី

ទ្រលុក ៖ ជាដាច់ខាត ម៉ែមិនឱ្យឯងទៅសង្ហា។

សង្ហា ៖ ខ្ញុំសូមអង្វរជាចុងក្រោយ

តា ៖ គ្មានចុងគ្មានដើមអីទេ អញមិនព្រម

សូភី ៖ អ្នកម៉ែ! កូនសូមអង្វរម្ដងទៀត

ទ្រលុក ៖ គ្មានម្ដងពីរដងអីទេ

តា ៖ ទេ ទេ!  អញមិនព្រម

ទ្រលុក ៖ ទេ ទេ! អញមិនព្រម

សង្ហា ៖ ដូច្នេះលាហើយលោកតា

សូភី ៖ ដូច្នេះលាហើយអ្នកម៉ែ។

### គូទាំងពីរក៏រត់ចេញទៅ

មីងផៃ និង មីងទា ស្រែកយំជាខ្លាំង ទទួលពួកមិត្តសង្ហាទាំងអស់មកដល់ មីងផៃក៏ទៅខ្សឹបប្រាប់ពួកនោះ។

ផៃ ៖ លោកអើយជួយផងសង្ហាទៅណាបាត់ទៅហើយ

ធា ៖ លោកអើយជួយផង! សូភីទៅណាបាត់ទៅហើយ

ទទួលពេលនោះលោកអាចារ្យនិងមីងនួនមកដល់ នាងទាទៅខ្សឹបប្រាប់

តា ៖ ទៅ! ជូនតាទៅតាមអាសង្ហា

ច្រលុកា ៖ ទៅជូនខ្ញុំទៅរកសូភីផង។

ដើរចេញរៀងខ្លួន វាំងននធ្លាក់

## ឈុតទី ៨

បើកវាំងននឡើងនៅក្នុងព្រៃជិតស្រុកឧត្តុង្គមានដើមឈើមួយធំ អាចជាដើមពោធិ ដូចទីស្ថានដែលនាងទាវ បានស្លាប់ ទទួលពេលនោះ ជាពេលជិតភ្លៀងផ្គរ គេឃើញមីងផៃនាំលោកតាភោគផល ដោយមាន មិត្តប្រុសស្រីរបស់សង្ខាចូលមកជាមួយផង។

តាភោគផល ៖ ឯណាទៅកាផៃ... វាចំណាំតែមកជួបគ្នាត្រង់ ណា។

ផៃ ៖ ចាសក្នុងព្រៃអស់ហ្នឹង ជួនកាលក៏ត្រង់ណោះ ជួនកាលក៏ ត្រង់ណោះ តែច្រើនជាងគេនៅក្រោមដើមឈើហ្នឹង

" ផ្គរ ភ្លៀង "

តា ៖ កាផៃ! ហាងឃើញទេ តែចិត្តអញមិនស្រួល ហើយ ទេវតាលើមេឃក៏មិនស្រួល ដែរ។

សាភយ ៖ រឿងសង្ខានិងនាងសូភីចង់ទៅជារឿងល្ខោន នាដកម្មមួយ... ដែលធម្មជាតិមែនៗ...

បន្លឺសំឡេងផ្គរ... មកជួយឱ្យកាន់តែសម្បើមផង...ដើមឈើនេះ ធ្វើឱ្យនឹកដល់ដើមពោធិដើងខាល ដែលនាងទាវព្រមទទួលសេចក្តី ស្លាប់ព្រោះស្នេហា...

តា ៖ ចៅៗ ទាំងអស់គ្នា... ជួយតាផង ដឹកនាំអាសង្ហាឱ្យវាមកផ្លូវត្រូវដូចជាចៅឯងទាំងអស់គ្នាវិញទៅ... ស្អីទៅស្លាប់រស់ប្តូរផ្តាច់អីជាមួយកូនអ្នកទ្រលុក... មីសូភីដែលខ្លួនវានេះមិនទាំងចេញឈ្មោះវាជាចៅតាផង... ទៅចែចង់តែប្រាំនាទីបាន... ស្រីអីក៏ចិត្តនោះធូរម្លេះ... វានេះទៀត... ថាបើចែចង់គេបាន... វានឹងមិនស្រឡាញ់ទេ...ឥឡូវអាសង្ហាទៅជាអាទុំទៅហើយ(ផ្គរ)

ឃើញទេ! ទេវតាដែលលោកឮខ្ញុំជួយបន្ទរឆ្លើយពីនោះមក

ដារ៉ា ៖ អើ... សង្ហា... នៅឯណា លោកតាឯងមករក... យើងទាំងអស់គ្នាមករក... អើតមុខមកមើល... ប្រធានក្រុមយុវជនមិនជឿលើស្នេហាទេ ឥឡូវលង់ក្នុងស្នេហាតើធ្វើមុខយ៉ាងម៉េច បង្ហាញឱ្យគេឯងឃើញមុខផងមើល... សង្ហា... សង្ហា...

ប៉ូល ៖ ឥតឆ្លើយ អារម្មណ៍គេជក់ជាប់តែនឹងសេចក្តីស្នេហា

លោកតា ៖ ទៅ! ចៅបំបែកគ្នាជួយរកវាផងមើល តាត្រូវបញ្ជាក់វានៅថ្ងៃនេះ ព្រោះតាទៅដណ្តឹងកូនគេឯកំពង់ឆ្នាំង... គេព្រមឱ្យទៅទៀតហើយណា... ស្រាប់តែវាទៅជាឆ្កួតក្បាលវិលក្បុងជាមួយនឹងមីសូភី... ស្រីប្រាំនាទីទៅវិញ ពួកក្មេងក៏ទៅរកប្រសេចប្រសាច

ផៃ ៖ ណ្ហើយលោកតា! អ្នកសង្ហាគេស្រឡាញ់សូភីដោយស្នេហាមែនៗ... ស្នេហាបរិសុទ្ធ ឈ្នះនៅលើចិត្តចង់ចំណេញអ្វីទាំងអស់ គួរណាស់តែលោកតា អាសូរដល់គូសង្សារកំសត់នេះ ...

លោកតា ៖ ឈប់និយាយមីកាផៃ! មកពីហាងនឹងណា

ផៃ ៖ យី! មកពីខ្ញុំ មកពីលោកតាហ្នឹងហើយ ព្រមឱ្យធ្វើពិសោធស្នេហា ពិសោធទៅវាបានមែន...

លោកតា ៖ អើអញឱ្យពិសោធ បើស្រឡាញ់អញមិនឱ្យយក បើមិនស្រឡាញ់អញឱ្យយក

ផៃ ៖ ជួយស្ដាប់ចុះ បើស្រឡាញ់មិនឱ្យយក បើមិនស្រឡាញ់ឱ្យយក ពង្រាត់បង្រាសគូគេ

លោកតា ៖ កាផៃ កាផៃ!... អាសង្ហានៅឯណា អញមានចៅតែមួយផងម្ដេចវាដាច់ចិត្តទៅចោលអញដូច្នេះ អញខំចិញ្ចឹមវាមក ថ្នមវា ឱ្យវាចាយតាមចិត្ត ឱ្យវាសប្បាយតាមចិត្ត... ឥឡូវស្រាប់តែវាដាច់ចិត្តទៅចោលឯងបាត់... រត់ទៅតាមស្រីឯណានោះទៅវិញ។

ផៃ ៖ លោកតាចិញ្ចឹមមនុស្សចង់បង្ខាំងមនុស្ស... ឱ្យធ្វើទៅតាមលោកតាទាំងអស់ ... ម្ដេចកើតមនុស្សគេមានខួរ គេមានគំនិត គេមានយោបល់ គេមានចិត្តដោយឡែកដែរណា។ លោកតា ខ្ញុំលើកដៃសំពះរាប់រយដងហើយ ថាខ្ញុំស្រឡាញ់សង្ហានេះដូចជាកូនខ្ញុំបង្កើតដែរ ខ្ញុំ

ឃើញការប្រយុទ្ធរបស់គេក្នុងសេចក្ដីស្នេហា ចង់បាននាងសូភីនោះធ្វើឡើងដោយពិបាកណាស់ ឃើញតែដង្ហើមធំ ឃើញតែមុខក្រៀមក្រំ អត់បាយក្រហាយទឹក ជួនកាលស្ងាត់ៗស្រក់ទឹកភ្នែកផង ព្រោះចិត្តម្ខាងចង់តាមមកខាងលើលោកតា ចិត្តម្ខាងទៀតស្នេហាសូភី វាទាញកន្ត្រាក់បានទៅហើយ... សង្ហាឥឡូវស្គមលោកតា មិនអាណិតគ្នាទេ... ព្រមឱ្យគ្នារៀបការជាមួយនាងសូភីទៅ...។

លោកតា ៖ ចុះពិសោធន៍ស្នេហានោះមិនខុសអស់ទៅហើយ

ផៃ ៖ ខុសឯណាត្រូវវិញទេតើ ពិសោធទៅឃើញថាស្រឡាញ់មែនដណ្ដឹងរៀបការឱ្យគេទៅវាចប់ទៅហើយ...

លោកតា ៖ ចុះអ្នកទ្រលុក ក្រែងគេមិនព្រមឱ្យសូភីមកអាសង្ហាដែរណា៎

ផៃ ៖ ជារឿងមួយដោយឡែកទៀត ហើយសូភីកំពុងតែពន្យល់អង្វរដែរ។

តា ៖ អញខ្មាសអ្នកទ្រលុកណាស់

ផៃ ៖ ឥតយករឿងខ្មាសគេមកទប់កម្លាំងស្នេហាបានទេ

តា ៖ ចុះកិត្តិយស កេរ្តិ៍ឈ្មោះអញ

ផៃ ៖ ឥតយកកិត្តិយស កេរ្តិ៍ឈ្មោះមកទប់កម្លាំងស្នេហាបានទេ

## ពួកខ្លះមកវិញ

លិនដា ៖ ដើរវាយព្រៃមើលតែរកឈ្លូសនៅតែមិនឃើញ

តា ៖ មកចៅៗទៅផ្ទះអ្នកទ្រលុក នៅជិតព្រៃនេះស្រាប់ សួរគាត់មើលរឿងអីបានជាបណ្តោយកូនស្រីមកទាក់ទងអាសង្ហាដូច្នេះ។

ផៃ ៖ ទៅ! អ្នកទ្រលុកគាត់កំពុងរកមុខលោកតានឹងអាលព្រលះ...

តា ៖ អើ! ទៅស៊ីសងគ្នាម្តងឱ្យដឹងសខ្មៅក៏បានដែរ។

## ទាំងអស់គ្នាដើរចេញទៅតាមលោកតា

សារាយ ៖ បក់ដៃហៅទីណូ ទីណូ! មកណេះមួយភ្លែត ទៅរកអម្បាញ់មិញខ្ញុំឃើញណា សង្ហានិងសូភី អង្គុយជិតគ្នាទាំងគូ ឃើញហើយគួរឱ្យអាណិត គួរឱ្យសរសើរថាក្នុងលោកនេះគ្មានអ្វីល្អជាងគូដែលស្នេហាគ្នាទេ។

ទីណូ ៖ យី! សារាយផ្លាស់គំនិតមួយទៀតហើយ ខ្ញុំស្រែកហៅលោកតាសិន លោកតា... សារាយប្រញាប់ខ្ទប់មាត់។

សារាយ ៖ នែ! បើយើងជាយុវជនវង្វេង គ្មានសំណាងទៅបានស្គាល់រសជាតិនៃសេចក្តីស្នេហាទេ កុំយកសម្រែកអាក្រក់របស់យើងទៅបំផ្លាញស្នេហាគេ ។

## ព្នាក្រៅ ពីរនាក់ដើរចេញទៅ

សង្ខានិងសូភីដើរចូលមក

សូភីរត់ធ្វើជាល្ខោន

នោ អើយនាងនោ កាំបិតស្លាកោរ នៅទុកឯណា

នាងនោក៏ឱ្យកាំបិតកោរទៅនាងទាវ នាងទាវក៏ចាក់ខ្លួន

សូភី ៖ បងកុំភ័យ ខ្ញុំមិនចាក់ខ្លួនដូចទាវទេ បងនាងទាវព្រម ស្លាប់ព្រោះការពារស្នេហាដ៏បរិសុទ្ធ ខ្ញុំ ខ្ញុំ! ព្រមរស់ព្រោះការពារស្នេហា បរិសុទ្ធ ។ បាត់ខ្ញុំពីផ្ទះដូច្នេះមិនដឹងជាអ្នកម៉ែព្រួយពីខ្ញុំយ៉ាងណាទេ អ្នកម៉ែអើយ អ្នកម៉ែចិញ្ចឹមកូន ស្រឡាញ់កូន ដូចម្ចាស់លលក ស្រឡាញ់លលក ហើយដាក់ក្នុងទ្រុងមាស ឥឡូវលលកកូនហើរចេញពីទ្រុងមាសលាអ្នកម៉ែហើយ អ្នកម៉ែច្បាស់ជាព្រួយហើយ តែសូមអ្នកម៉ែជ្រាបថា កូនបែកពីម៉ែនេះ មិនមែនទៅរកទុក្ខទេ គឺទៅរកសុភមង្គលតាមសត្វលោកដែលកើតឡើងក្នុងវត្តសង្សារ... ។

សង្ខា ៖ លោកតាបង និងពួកម៉ាកបង តែងពោលថា អាណិតបងណាស់ព្រោះបងនេះមានទុក្ខ ទុក្ខស្នេហា តែបងទេដែលត្រូវអាណិតលោកតានិងពួកម៉ាក លោកតាបងដោះខ្លួនគាត់ឱ្យផុតពីភោគសម្បត្តិពុំបាន មួយថ្ងៃៗ គ្មានឮពាក្យផ្អែមល្ហែមសោះ ឮតែចំណោញខាត

ខាតចំណេញ រីឯចិត្តបងវិញ តែលតោលក្នុងជីវិតឥតកោះត្រើយ មិនដឹងជាត្រូវធ្វើអ្វីក្នុងជីវិតនេះឱ្យច្បាស់ កើតមកហើយមិនដឹងជាត្រូវទៅណាមកណា ថែមទាំងមិនស្គាល់ថានេះខុសនេះត្រូវផង គេប្រយុទ្ធនឹងការអផ្សុកដោយយកស្រា យករាំមកធ្វើជាគ្រឿងជំនួយ។ ហើយដើម្បីជាកិច្ចបញ្ឆោតចិត្តលួងលោមចិត្តអាត្មានោះ ក៏បញ្ចេញទ្រឹស្តី មិនចេះអស់មិនចេះហើយ ជេរបន្ទោសមនុស្សជាតិមិនឈប់ឈរ តែមិនគិតរកផ្លូវដោះស្រាយជាស្ថាពរបែបណាមួយសោះឡើយ។ អូនអើយ! កាលបងនឹកទៅដល់មួយខែមុន ដែលបងលង់ខ្លួនស្ថានភាពនេះ នោះបងខ្លាចព្រឺខ្លួនខ្លាក ព្រោះពេលនោះបងយល់ថា មនុស្សគ្រាន់តែជាដុំឧសសំណាត់មួយដុំ រសាត់បក់បោកដោយរលកសាគរ តែឥឡូវបងបានប្អូនបងបានស្នេហារបស់ប្អូនមកគូស។ គំនូសបន្ទាត់ជីវិតឱ្យបងដើរហើយយើងទាំងពីរដើរកៀកដៃគ្នា លុះត្រាតែរលត់សង្ខារឥតមានលោកតាបងអ្នកម៉ែប្អូន ឥតមានចំណេញប្រាក់ឥតមានចំណេងកិត្តិយសមកឃាំងឃារាំងផ្លូវយើងបានឡើយ...។

## ផ្គរ

**សូភី ៖** ខ្លះឮផ្គរ ថាជាសំឡេងថ្ងូរសម្ដែងទុក្ខ ដែលទេវតាផ្ដន្ទាដល់ខ្លួន ចំពោះប្អូនវិញសំឡេងផ្គរ សំឡេងខ្យល់ សំឡេងបក្សា ជាតន្ត្រីប្រគំឡើង ដើម្បីកំដរសេចក្ដីស្នេហារបស់យើងដែលពុំទាន់មាន

ភ័ព្វសំណាង បានសម្រេចដោយអាពាហ៍ពិពាហ៍ ហើយមានតន្ត្រីបុរាណខ្មែរ នោះជួយកំដរផង...។

**សង្ហា ៖** យី! ឮសូរអ្វី នរណាទៀតមករំខានយើងក្នុងព្រៃដ៏ស្ងៀមស្ងាត់នេះ ម៉ែអូនទេតើ អូមានមីងទា មីងនួននិងលោកតាអាចារ្យមកផង ទៅអូន! ទៅពួនសិនទៅ កុំអាលប្រឆាំងនឹងគាត់ ព្យុះកំពុងខ្លាំងណាស់ យើងទៅ ក្រាបពួនឱ្យផុតខ្យល់សិន...។ ព្យុះ។ ពីរនាក់រត់ពួន ។

**ទ្រលុក ៖** ឯណាកាទា! វាចំណាំតែមកជួបគ្នាកន្លែងណា?

**ជាង៉ា ៖** ចាំ! ក្នុងព្រៃអស់ហ្នឹង ជួនកាលត្រង់ណោះ ជួនកាលត្រង់ណោះ តែច្រើនជាងគេព្រៃអស់ហ្នឹង។

## ផ្គរ ភ្លៀង

**ទ្រលុក ៖** កាទា! ហងឃើញទេ តែចិត្តអញមិនស្រួលហើយទេវតាលើមេឃ ក៏មិនស្រួលដែរ

**អាចារ្យ ៖** រឿងសង្ហានិងសូភីចង់ទៅជារឿងល្ខោននាដកម្មមួយដែលធម្មជាតិមែនៗ បន្លឺសំឡេងផ្គរមកជួយឱ្យកាន់តែសម្បើមផង។ ដើមឈើនេះ ធ្វើឱ្យនឹកដល់ដើមពោធិជើងខាល ព្រមទទួលស្លាប់ព្រោះស្នេហាក្នុងរឿងទុំទាវ។

ទ្រលុក ៖ នួន! លោកអាចារ្យជួយជុំផង ពន្យល់មីសូភីថា កុំឱ្យទៅបំបាក់មុខខ្ញុំទៅស្រឡាញ់ចៅតាប៉ិក ភោគផលដែលដណ្ដឹង ហើយឱ្យឈ្នួលមកជូនពាក្យ រួចឱ្យអាចៅមកធ្វើពុតជាបាក់ដៃពិសោធស្នេហាក៏វាលិចកញ្ចង់លង់កញ្ជើតាំងពីនោះមក ល្បីពេញមួយភូមិទាំងអស់គ្នា គេហៅមីសូភីថា នាងទាវ... ហើយថាខ្ញុំជូនផាន់ៗ ចង់យំៗ ណាមួយខ្ញុំខំទៅនិយាយលោកបាឡាត់ឱ្យគេមកដណ្ដឹង គេព្រមទៅ ហើយត្រូវសម្រេចឆាប់ឆាប់ផង ងាប់ហើយខ្ញុំ ។

ឆ្នួន ៖ ភីអើយនៅឯណា ម៉ែឯងមករកណា៎

អាចារ្យ ៖ លលកដែលបានហើរចោលទ្រុងរួចទៅហើយ មិនងាយអន្ទងហៅឱ្យមកចូលទ្រុងវិញបានទេ ទោះបីទ្រុងនោះធ្វើឡើងដោយមាសក៏ដោយ ។

ធា ៖ អ្នក! ខ្ញុំអាណិតនាងភីណាស់ នាងភីស្រឡាញ់សង្ហាមែនៗ ហើយឥតទាន់មានការប៉ះពាល់ដែលមិនសមរម្យនោះទេ បើគេស្រឡាញ់គ្នាដូច្នេះ រៀបការឱ្យគេទៅ ។

ទ្រលុក ៖ ស្អី! ភ្ជាប់ជាមួយតានោះវិញកើត

ធា ៖ មិនមែនរៀបការជាមួយតានោះទេ រៀបការឱ្យអ្នកសង្ហាណា នាងសូភីព្រួយចិត្តពីរឿងនេះ លែងញ៉ាំបាយញ៉ាំទឹក ឥឡូវណោះស្គម ស្រកសាច់អស់សន្ធឹក ខ្ញុំអាណិតនាងភីណាស់ ។

ឪលុកា ៖ អាចៅនោះវាមធ្យមទេ ក្មេងវាមិនដឹងអី យើងមិនប្រកាន់ក៏បានដែរ ចុះតានោះឡើងឯងពិសោធន៍ស្នេហាអីដែរ? ពិសោធថាស្រឡាញ់មិនឱ្យរៀបការ ចាស់ព្រើល

អាចារ្យ ៖ ណ្ហើយ! នៅទីនេះមិនឃើញគេទេ តែខ្ញុំជឿថា ទោះម្ដេចម្ដាក៏នាងភីនេះមិនដាច់ចិត្តដើរចោលទ្រនំ ដើរចោលអ្នកម៉ែគេដែរ។

ឪលុកា ៖ មិនចោលឯណាវាបាត់ពីផ្ទះ ទៅហើយ

ឆ្នួន ៖ អើ! បើយើងធ្វើឱ្យគ្នានៅតទៅទៀតមិនកើតអីថា។

ឪលុកា ៖ ឱ! សូភីកូនមាសម្ដាយ ម៉ែមានកូនតែមួយខំចិញ្ចឹមមិនឱ្យខ្ទោះតាំងពីតូចមកមិនឱ្យហ៊ានទៅណាឆ្ងាយពីម៉ែទេ មិនហ៊ានឱ្យស្គាល់ទាក់ទងប្រុសឈ្មោលឯណាទេ។ ដើម្បីកុំឱ្យកូនល្ងង់ម៉ែខំជួលគេឱ្យមកបង្រៀនអក្សរ អ្នកនាំដល់ផ្ទះ គ្រូនោះទៀតមិនហ៊ានយកគ្រូប្រុសទេ យកតែគ្រូស្រី ម៉ែទៅពឹងយាយជីចាស់ៗ ឱ្យមកបង្រៀនធម៌អាថ៌កូនឱ្យកូនយល់លំអានព្រះពុទ្ធសាសនា ព្រោះម្ដាយចង់ឱ្យនាងជានារីខ្មែរតួយ៉ាង...

អាចារ្យ ៖ យ៉ាងម៉េចទៅនារីខ្មែរតួយ៉ាងនោះ

ឪលុកា ៖ គឺវាលុះដំបូន្មានម៉ែឪ

អាចារ្យ ៖ ចុះបើជំបូន្មាននោះខុស ?

ទ្រលុក ៖ ឃើញទេសូម្បីតែលោកអាចារ្យឯងក៏ចោទថាខ្ញុំជាជូនផាន់ម្ដាយនាងទាវដែរ

ឆ្នួន ៖ ខ្ញុំហើយធ្លាប់និយាយថា សូភីជានារីតួយ៉ាង ទោះបីដល់ថ្ងៃហ្នឹងហើយក៏ខ្ញុំនៅតែចាំថាសូភីជានារីតួយ៉ាងដដែល ។

ធាជ័ធា ៖ ចាស! ឥតមាននាងឯណាឱ្យល្អដូចពេជ្រទាំងគ្រាប់ដូចនាងសូភីទេ។

ទ្រលុក ៖ ខូចពីតាភោគផលហ្នឹងណា បានតែជួបមុខប្រលះតាហ្នឹងឱ្យអស់ដៃម្ដង

ធា ៖ នាងភី នាងភី នៅឯណា ?

**ដើរចេញទៅ ទាំងអស់គ្នាទៅតាម ។**

**សង្ហានិងសូភីចូលមក។**

សូភី ៖ បងខ្ញុំត្រូវតែលាបងសិនហើយ ចិត្តខ្ញុំចំពោះបង ការតស៊ូរបស់ខ្ញុំចំពោះស្នេហាបរិសុទ្ធយើង ខ្ញុំសង្ឃឹមថាបងឥតមានមន្ទិលសង្ស័យអ្វីទៀតទេ ពេលនេះម្ដាយប្អូនដូចជាឆោឡោនឹងប្អូនណាស់។ ម្ដាយឪពុកជាព្រះនៅក្នុងផ្ទះ កូនពុំត្រូវធ្វើឱ្យអ្នកមានគុណទាំងនោះពិបាកចិត្តដោយសារទេ។ ប្អូនលាបងទៅនៅនឹងអ្នកម៉ែ ថ្ងៃនេះគាត់ខឹង

ប្អូនពុំតបត ថ្ងៃស្អែកគាត់អន់ខឹង កិរិយាបង្ហាញថាស្រឡាញ់តែបងមួយ យូរៗទៅលែងអីនឹងអាណិតកូន នៅពេលនេះបងនិងប្អូននឹងបាន ស្គាល់សុភមង្គលដោយអ្នកមានគុណព្រមរំលែកសុភមង្គលនេះជាមួយ ផង។ ចំណែកបងៗ ក៏ត្រូវប្រព្រឹត្តអាកប្បកិរិយាបែបខ្ញុំនេះចំពោះ លោកតារបស់បង... លោកតាបងគង់ត្រឡប់ចិត្តមកតាមបងមិនខាន លោកតាបងក្ដី អ្នកម៉ែខ្ញុំក្ដី សុទ្ធតែជាសប្បុរសជនមានធម៌ ថ្ងៃណាមួយ គង់គុណសម្បត្តិល្អ របស់គាត់នោះទៅបង្រ្កបឈ្នះលើការលោភលន់ ការយល់ច្រឡំពីកិត្តិយសមិនខាន។

សង្ហា ៖ អូននិយាយត្រូវទាំងអស់ អូនមិនមែនគ្រាន់តែមាន យោបល់ល្អ មានចិត្តក្លាហានទេ តែអូនជាស្រីចេះមានមធ្យោបាយសម សួនទៀត ដើម្បីសម្រេចបំណងស្នេហារបស់យើង តែបើបងមិនចង់ឱ្យ អូនបែកទៅពីបងនៅពេលនេះ ព្រោះចិត្តបងវិស័យដូចជានៅខ្សោយ ណាស់ បើឥតមានចិត្តអូនមកជួយគាំពារបង ច្បាស់ជា... ឬមួយធ្លាក់ ទៅក្នុងក្ដីអស់សង្ឃឹម ឬមួយនឹងទៅប្រព្រឹត្តអំពើខុសបែបណាមួយមិន ខាន នាងទាវគិតពុំទាន់ហើយបានផ្លាស់ផ្ដាច់សង្ខាររបស់ខ្លួនក្រោមដើម ឈើបែបនេះ ។

ឱ! ព្រលឹងនាងទាវដែលនៅរស់ជានិច្ចជាកាលអើយ យើងជា គូកំសត់ ដូចទុំនិងអ្នក ព្រលឹងអ្នកទាំងពីរនៅស្ថានណា មកជួយយើង ក្នុងពេលនេះផង។

## សង្ខាលុតជង្គង់ នាងសូភីធ្វើតាមដែរ

## សូភីបញ្ចេញកាំបិតកោរ

*សូភី* ៖ ទាវនាងបានផ្តាច់សង្ខារក្រោមដើមឈើដូច្នេះដោយកាំបិតស្លាបែបនេះ នាងបានចង្អុលប្រាប់ម្តាយរបស់នាង ប្រាប់មហាជនទាំងប្រទេសថា កម្លាំងស្នេហាបរិសុទ្ធអាចនាំទៅដល់កម្រិតទីបំផុតមួយគឺមរណៈបាន សូមឱ្យឧទាហរណ៍របស់នាងទៅជាមេរៀនមួយសម្រាប់បើកភ្នែកអ្នកផង សម្រាប់

*( បាត់ខ្លឹមសារអត្ថបទចំនួន២ទំព័រ)*

ទ្រលុក ៖ ពីណាដើមភ្លើង ?

តា ៖ ស្រីវាដើមភ្លើង !

ទ្រលុក ៖ យី! យី! ចង់ស្ទុះទៅវាយតែយំ។ អ្នកផងចាប់

ឆ្លូង ៖ ណេ្ហីយ! ទ្រលុកអើយ ទៅជាមកឈ្លោះប្រកែកគ្នាអីកណ្ដាលព្រៃ

អាចារ្យ ៖ ជម្រាបសួរលោកតា អាល័យតែស្រឡាំងកាំងខានឯជម្រាបសួរ រួចចុះទៅណាក៏ច្រើនម្លេះ

ឌីណូ ៖ ពួកខ្ញុំនេះជាមិត្តចិត្តមួយថ្លើមមួយរបស់សង្ខាមិនដែលបែកគ្នាពីសង្ខាបានមួយថ្ងៃទេ តែតាំងពីគេ នែ! នែ! ស្នេហាផ្កាសូភីមកនែ...

ទ្រលុក ៖ នែ! ឯងកុំចេះដៀមដាមអីណាស់ ល្អមើលណាស់លោកតា នាំក្មេងមួយហ្វូងបះពីព្រោះស្នេហា

តា ៖ ខាងណេះក៏ល្អមើលដែរ នាំគ្នាមកអស់ហើយព្រោះស្នេហា

ឆ្លូង ៖ នែ! ខ្ញុំរក្សាសីលមែនទែន ហើយនាំគ្នាមកនេះក៏មិនមែនមកពីរឿងស្នេហាដែរ គឺមករកក្បួយសូភីដែលគេចាប់

តា ៖ យី! អាណាចាប់ មើលចោទថាសង្ខាចាប់ ឮដល់តុលាការ

មិនងាប់ហើយ

**ទ្រលុក** ៖ បើមិនចាប់ស្អី កូនគេនៅសុខៗនាំគ្នាធ្វើពិសោធស្នេហាបាក់ដៃ ទាល់តែអីចឹង។

**តា** ៖ អើ! ពិសោធទៅវាហុចលទ្ធផលមែន មិនចេះប្រដៅកូនឃើញប្រុសមក ហើយបានប្រាប់ឈ្មោះអាសង្ហាផង ភ្លេតទៅហើយ។

**ទ្រលុក** ៖ មិនចេះប្រដៅកូន ពុទ្ធោអើយ! ជួយស្តាប់ខ្ញុំចុះ ខ្ញុំមិនចេះប្រដៅកូន រីឯគាត់ដែលចេះប្រដៅថៅបែរជាព្រមបណ្តោយឱ្យវាមកធ្វើជាត្លុក បញ្ឆោតគ្រួសារត្រឹមត្រូវហ្នឹងហើយចេះប្រដៅថៅ...

**តា** ៖ អើ! ចេះប្រដៅហើយ

**ទ្រលុក** ៖ ចេះហើយបានជាថៅរត់ចោលលើកគ្នាមកតាមពេញព្រៃ ដូចតាមឈ្លូស

**តា** ៖ ព្រោះវាដោយឈ្លូសញី។

**ទ្រលុក** ៖ យី! ប្រមាថកូនខ្ញុំថាឈ្លូសញីឬព្រលះតានេះម្តង

**ស្ទុះទៅវាយ។ តួសង្សារពីរនាក់ចេញមក**

**ស្ទូភី** ៖ ឈប់! អ្នកម៉ែ

**សង្ហា** ៖ ឈប់! លោកតា

ទ្រលុក ៖ កូនមាសម្ដាយ ម្ដាយមករក

តា ៖ ចៅមាសជីតា ជីតាមករក ទៅណាចោលតាបាត់

ពួកមិត្ត ៖ សង្ខា! សង្ខា!

ឆាជ័ឆា ៖ សូភីក្អួយ

ដៃ ៖ សង្ខាក្អួយ

អាចារ្យ ៖ នែ! ឥឡូវជួបជុំហើយទៅណា ទៅផ្ទះខាងស្រី ឬផ្ទះខាងប្រុស នៅក្នុងព្រៃដូច្នេះមិនកើតទេ

ទ្រលុក ៖ ស្អី! ផ្ទះខាងប្រុសខាងស្រីអី សូភីវាទៅផ្ទះយើងវិញ រួចគេគេទៅណាទៅទៅ ...

តា ៖ ទៅសង្ខាទៅផ្ទះចៅ

មិត្ត ៖ ទៅលេងភ្លេង

តា ៖ ចៅតា! កូនគេអ្នកកំពង់ឆ្នាំងតាបានដណ្ដឹងគេ គេព្រមបានទាំងជូនប្រាក់ទៅគេខ្លះទៅហើយ ចៅអាណិតតា ចៅត្រូវគោរពតាពាក្យពិសោធន៍ស្នេហាដែលបានល័ក្ខខ័ណ្ឌជាមួយតា ចៅតាមតា តារៀបប្រពន្ធថ្មីឱ្យសម្បត្តិប៉ុន្មានតាប្រគល់ឱ្យទាំងអស់។

ទ្រលុកា ៖ សូភីកូនម្ដាយ! ម្ដាយមានតែកូនមួយទេ ជាដួងជីវិតរបស់ម្ដាយ ម្ដាយបានលើកកូនទៅឱ្យលោកបាឡាត់ហើយ ត្រឡប់ទៅផ្ទះវិញ ទៅរៀបការតាមប្រពៃណីខ្មែរយើង ម្ដាយមិនអួតអាងថាមានសម្បត្តិផ្ទះ២០ល្វែង រឹទ្បា៥ លុយទាំងការុង ពេជ្រឱ្យកូនដូចគេទេ តែសម្បត្តិដ៏តិចតួចរបស់ម្ដាយ ម្ដាយឱ្យកូនទាំងអស់ ហើយសំខាន់បំផុត ម្ដាយយកចិត្តម្ដាយធ្វើជាតម្លៃចងដៃកូន។

សង្កា ៖ លោកតាអាចារ្យឃើញទេ រកកន្លែងគួរសមសិនទៅ យើងពុំដឹងថានឹងត្រូវត្រឡប់ទៅផ្ទះខាងណាឡើយ។

អាចារ្យ ៖ អើរ៉ឺ! នែ! អានួន គិតរកកន្លែងអង្គុយឱ្យស្រួលសិនទៅ

សារាយ ៖ ពួកយើងមកត្រង់ណេះមក បានមើលឃើញ មុខតួកំសត់ទាំងពីរនេះចំពីខាងមុខ ផ្គរ ផ្គរ ផ្គរ ផ្គរ ។

សង្កា ៖ ផ្គរនេះបញ្ជាក់ជាចុងក្រោយថា ពពកខ្មៅដែលពពូនពពាក់លើមេឃា អម្បាញ់មិញក៏រសាត់ជាលំដាប់ ។ លោកតាអ្នកមីង ម៉ែផៃ មីងទា លោកតាអាចារ្យ មីងនួន មិត្តទាំងអស់ កុំឱ្យមានចិត្តសង្ស័យឱ្យសោះថាយើងទាំងពីរជាសត្រូវចំពោះអ្នកមានគុណ និងមិត្តទាំងអស់ បើស្ថានការណ៍កើតឡើងដោយការមិនយល់គ្នា ប្រាន

យើងទាំងអស់មកដល់កន្លែងនេះ ពពកខ្មៅរសាត់ទៅហើយ គួរយើងកំចាត់ពីគំនិតយើងទាំងអស់គ្នា នូវចិត្តមន្ទិលសង្ស័យ លោកតា អ្នកមីងជំរះចេញនូវការប្រកែប្រកាន់ដ៏តិចតួច ដើម្បីឱ្យគំនិតនោះថ្លាឡើង កុំឱ្យល្អក់ឱ្យសោះ ជួយទទួលអបអរសេចក្ដីស្នេហាបរិសុទ្ធរបស់យើងដែលថ្លាយង់ដូចវង់ព្រះចន្ទពេញបូណ៌មី ។

តា ៖ តាំងពីដើមមក តែទុកឱ្យអាហ្នឹងនិយាយវាចេះតែព្រោកប្រាជ្ញទៅ ស្ដាប់វាខ្លបត្រចៀក វរ វរ! តាមវា ភ្លេចកូនក្រមុំអ្នកកំពង់ឆ្នាំងនិងប្រាក់ប្រចាំចិត្ត ។ ស្ទុះទៅទាញដៃ ។ ទៅ! ទៅផ្ទះ ។

សង្ហា ៖ ផ្ទះឯណា ?

តា ៖ យី! ផ្ទះឯណា ឯងមានផ្ទះឯណា សួរអញថាផ្ទះឯណា

**អ្នកទ្រលុកចូលទៅទាញដៃកូន នាងនោះនិយាយថា**

សុភី ៖ អ្នកម៉ែ! កុំអាលសិន លោកអ្នកទាំងអស់គ្នាស្ដាប់ខ្ញុំសិនស្ដាប់សំឡេងនារីម្នាក់ពុំដែលបានរៀនជ្រៅជ្រះ ហើយពុំបានទាក់ទងសេពគប់នឹងស៊ីវិល័យក្រៅផង ម៉្លោះហើយពាក្យសម្ដីដែលខ្ញុំនិយាយទោះបីមានខុសឆ្គងខ្លាំង ពាក្យទាំងនោះច្បាស់ជាមានតម្លៃត្រង់ថាពាក្យពិត ពាក្យដុះពីចិត្ត ចេញពីក្រអៅបេះដូងនារីមែនៗ មិនក្លាយទៅ

តាមសៀវភៅឬខ្សែភាពយន្តណាមួយទេ ចិត្តនារី នេះចង់ជម្រាបអ្នកម៉ែថា គូស្នេហ៍កូនតែមួយក្នុងជីវិតនេះ គឺបងសង្ហានេះ។ ឥតមានការចំណេញលុយកាក់ ឥតមានការយល់ច្រឡំពីកិត្តិយស ឥតមានកម្លាំងអ្វីមកបំបែកខ្ញុំពីបងសង្ហាបានឡើយ ម្ល៉ោះហើយខ្ញុំសូមលើកម្រាមដៃដប់អង្វរ អ្នកម៉ែ អង្វរលោកតា អង្វរមីងទា មីងផៃ មីងនួន លោកតាអាចារ្យ និងមិត្តទាំងអស់ថា សូមទទួលអបអរសាទរនឹងសេចក្ដីស្នេហានៃយើងទាំងពីរនេះផងចុះ ព្រោះឥតនៅមានសេចក្ដីសង្ស័យបែបណាមួយទៀតទេ ដែលថាអាចបំបែកយើងបាននោះ។

**សារាយ ៖** ស្ទុះទៅឱបសូភី សូមឱ្យមិត្តស្គាល់តែសេចក្ដីសុខចម្រើន ។

**ធីណា ៖** យី! សារាយ

**ប៉ូល ៖** មើល! មើល ...

**សារាយ ៖** មែនហើយមិត្តពីថ្ងៃនេះទៅ ខ្ញុំប្រែគំនិតហើយ ខ្ញុំយល់ថា យុវជនមិនជឿលើកម្លាំងនិងភក្ដីភាពរបស់ស្នេហា ដាយុវជនដែលតែលតោលដូចយើងទាំងអស់គ្នា ជីវិតអណ្ដែតត្រសែតឥតយល់ថាជីវិតសាបដូចសម្លឥតអំបិលប្រហុក។ ខ្ញុំដឹងថាមែនហើយ ក្នុងជីវិតមនុស្សមានស្នេហាបន្លំ ស្នេហារាយមាយ ស្នេហាក្បត់ចិត្ត ស្នេហាជំនួញ

ស្នេហាចំណោញ។ ប៉ុន្តែលើសពីសេចក្តីស្នេហាមិនបរិសុទ្ធទាំងប៉ុន្មាននេះចេញ គង់នៅមានស្នេហាភក្តី ស្នេហាតែមួយដែលមានរស្មីត្រចះត្រចង់ ហើយដែលមនុស្សទាំងអស់គ្នា ត្រូវតែប៉ងប្រាថ្នាប្រវេប្រវាឱ្យបានទៅស្គាល់រសជាតិនៃស្នេហានេះ ដែលមិត្តសង្ហានិងសូភីកំពុងតែត្រេកត្រអាល។

សង្ហា ៖ អរគុណហើយសារាយ អរគុណទាំងអស់គ្នាដែលបានធ្វើជាសាក្សីនៃស្នេហាបរិសុទ្ធយើងនេះ

អាចារ្យ ៖ ណ្ហើយ! លោកតា អ្នកអើយ ព្រះពុទ្ធក៏គង់បានសម្តែងថា ការពង្រាត់បង្រាសគូសង្សារគេនេះជាអំពើចងកម្មពៀរធំណាស់ណា

ផៃ ៖ លោកតា! ខ្ញុំអាណិតក្មួយសង្ហាណាស់

ជាជ័ជា ៖ អ្នកសូភីស្គមសន្ធឹក

ឆ្នូន ៖ ណ្ហើយ! ទ្រលុកអើយ ពីដើមក៏ឯងថាចង់តែឱ្យទៅលោកតានេះដែរ ចុះបើវាអីចេះទៅហើយ គួរតែត្រូវអេបអរទៅវិញទេ។

ទ្រលុក ៖ ចៅនោះមានអី ស្អប់តែតា

តា ៖ បើប្រាសមកឯងទៀតហើយ ឱ្យអាសង្ហាទៅធ្វើកូនប្រសាម៉េចបាន

ទ្រលុក ៖ មិនបានហីទៅ

តា ៖ ថាហី! ហី! ហើយ

ទ្រលុក ៖ ទៅសូភីទៅផ្ទះ

តា ៖ ទៅអាសង្ហាទៅផ្ទះ

អាចារ្យ ៖ ថាទៅ! ទៅ! ហើយតែទៅផ្ទះណា?

ឆ្ងួន ៖ ណ្ហើយ សង្ហាទៅផ្ទះលោកតាសិនទៅ សូភីមកផ្ទះម៉ែឯងសិនមក រួចសង្ហាចូលស្ដីដណ្ដឹងតាមច្បាប់ទំលាប់ជាថ្មីម្ដងទៀតទៅ សូមចាត់ការរបៀបនេះទៅ

ផៃ ៖ ធ្វើអ៊ីចឹងត្រូវ

ឆាង៍ឆា ៖ មែន! ត្រូវមែន

វិទ្ធី ៖ ម៉េចសង្ហាព្រមទេ? ពួកយើងទាំងអស់គ្នាយល់ព្រមហើយ!

អាចារ្យ ៖ បើនិយាយពីស្រុកឥឡូវឃើញថាភាគច្រើនណាស់ហើយណ៎ា

ផៃ ៖ ម៉េចទៅលោកតា?

តា ៖ ចុះខាងគេ គេថាម៉េច?

ឆាង៍ឆា ៖ ម៉េចទៅអ្នក?

ទ្រលុក ៖ ចុះខាងគេ គេថាម៉េច?

នាងផៃនិងនាងទា ខ្សឹបដាក់គ្នា រួចផៃទៅជួបលោកតា ទាទៅជួបទ្រលុក និយាយជម្រាបស្មើគ្នាថា

ទ្រលុក ៖ និយាយជម្រាបស្មើគ្នាថា

នាងផៃ ៖ លោកតា ខាងគេយល់ព្រមហើយ

នាងទា ៖ អ្នកខាងគេយល់ព្រមហើយ

តា៖ បើគេយល់ព្រមអញក៏យល់ព្រមដែរ

ទ្រលុក ៖ កាទា! បើគេព្រមអញក៏ព្រមដែរ។

**ចប់**

ក្រសួងឃោសនាការនិងក្រសួងសន្តិសុខជាតិបានត្រួត ហើយអនុញ្ញាតឱ្យសម្ដែងតាមនេះ កាលពីថ្ងៃទី៤ មិថុនា ១៩៦៤ (និងថ្ងៃ៨ មិថុនា ១៩៦៤)ដោយបានចុះលេខ ២១៥